KhmerPost USA
Advertising: **PA/NJ/NY: (267) 253-3947/ CT: (860) 461-3687**
**MA/RI: (978) 656-8141/ (781) 244-0522**

**មាតិការឿង** Vol 06 Issue 118 Nov. 25th - Dec. 7th. 2012 **ទំព័រ**

១-ដល់ពេលអ្នកមាន និងអ្នកក្រ (ដោយ គីម សុស)..............០៣
២-សុខភាព និងម្ហូបអាហារយើង..............០៤
៣-ខេមបូឌា ដេលី..............០៦&០៧
៤-ក្ដុបូលវីណេតរាយការណ៍ពីបរិស្ថាន..............០៨
៥- ប្រវត្តិវណ្ណសិល្បជាតិរំដោះប្រជាពលរដ្ឋខ្មែរ(ដោយ ម៉ម ឃឹន)..១៥
៦- ប្រាសាទភ្នំដាតំបន់អតីត..............២០

32 Wamesit St., Lowell, MA 01852. **Phone-Fax (978) 656 8141** www.khmerpost.us

# អូបាម៉ា ដំណើរប្រវត្តិសាស្ត្រទៅកម្ពុជា



**ខ្មែរផុស** : លោក បារ៉ាក់ អូបាម៉ា បានសម្ដោច អាណត្តិថ្មីថ្ងៃទីពីរជាប្រធានាធិបតី ស.រ.អា របស់លោកទៅកាន់ប្រទេសពីរនៅអាស៊ីដែលមានបញ្ហាលទ្ធិប្រជាធិបតេយ្យយ៉ាងធ្ងន់ធ្ងរគឺទៅភូមា ដែលយោធាពុំព្រមផ្ទេរអំណាចឱ្យទៅស៊ីវិល និងទៅប្រទេសកម្ពុជា ដែលមានការរំលោភយ៉ាងធ្ងន់ធ្ងរលើការគោរពសិទ្ធិមនុស្ស សូមអានអត្ថបទរាយការណ៍របស់ **ខេមបូឌា ដេលី នៅទំព័រក្នុង**

# ឡូវែល: សមាគមខ្មែរអាយុ៣០ឆ្នាំ




**ខ្មែរផុស ស.រ.អា**

សមាគមខ្មែរនៅឡូវែលបានបើកពិធីជប់លៀងប្រចាំឆ្នាំដ៏ត្រចះត្រចង់មួយនៅភោជនីយដ្ឋានប៉ៃលិនស្ថិតនៅកណ្ដាលមណ្ឌលក្រុងខ្មែរ ដោយមានភ្ញៀវសំខាន់ៗក្នុងតំបន់ចូលរួមប្រមាណ៣០០នាក់ នារាត្រីថ្ងៃសៅរ៍ ទី១០ខែវិច្ឆិកា ឆ្នាំ២០១២កន្លងទៅ។ **តទៅទំព័រទី 19**

# មន្ត្រីជាន់ខ្ពស់គណបក្សសង្គ្រោះជាតិ២រូបធ្វើដំណើរទស្សនកិច្ចមកកាន់ ស.រ.អា




លោកស្រី មូរ សុខហួរ ជាតំណាងរាស្ត្រ និង លោកប៉ុល ហំម ជាអ្នកនាំពាក្យគណបក្សសង្គ្រោះជាតិ ដែលជាគណបក្សជំទាស់ធំជាងគេនៅប្រទេសកម្ពុជា បានធ្វើដំណើរមកបំពេញបេសកម្មពិសេស ជួបជាមួយមន្ត្រីសំខាន់ៗនៃរដ្ឋាភិបាល ស.រ.អា និងជួបសួរសុខទុក្ខដល់បងប្អូនរួជាតិខ្មែរជាច្រើន ដូចជានៅរដ្ឋធានីវ៉ាសិនតោនឌីស៊ី រដ្ឋវៀហ្ស៊ីនីញ៉ា រដ្ឋកាលីហ្វ័នីញ៉ា រដ្ឋវ៉ាស៊ិនតោន រដ្ឋម៉ាស្សាឈូសេត រដ្ឋផែនស៊ីលវេនីញ៉ា និងរដ្ឋអ៊ីលីណយជាដើម ។

នៅថ្ងៃទី៣វិច្ឆិកា ឆ្នាំ២០១២ មន្ត្រីជាន់ខ្ពស់ ទាំង២រូបបានអញ្ជើញមកដល់ក្រុងហ្វីឡាដែលហ្វៀ ដើម្បីជួបសួរសុខទុក្ខ និងសំណេះសំណាលជា មួយសកម្មជន **តទៅទំព័រទី ៩**

# ខ្មែរនៅ DANBURY មានជីវភាពប្រសើរ

**ដោយៈ ខ្មែរផុស ស.រ.អា**

"ដាន់ប៊ូរី"ជាក្រុងតូចមួយភ្ជាប់ទៅក្រុងញូយ៉កស្ថិតនៅពាក់កណ្ដាលផ្លូវពីហ្វីឡាដែលហ្វៀ ទៅ ឡូវែល លើផ្លូវលេខ៨៤ ។ នៅទីនោះប្រជាពលរដ្ឋខ្មែរមានប្រមាណជា



២០០០នាក់ រស់នៅដោយឧស្សាហ៍ជួបជុំគ្នាធ្វើបុណ្យ ឬក៏រៀបជប់លៀងបុណ្យកំណើត... ។ល។

ថ្ងៃអាទិត្យទី១១ វិច្ឆិកានេះ ភ្ញៀវខ្មែរប្រមាណ៨០នាក់ទៅ១០០នាក់ បានទៅជួបជុំគ្នានៅគេហដ្ឋានរបស់ "ឌីម៉ង់"មែន នឹងនាងឆេងស្រីមុំ ដើម្បីធ្វើបុណ្យ១០០ថ្ងៃ ជូនម្ដាយដែលបានចែកឋានទៅដោយជំងឺមហារីកដើមទ្រូង គឺអ្នកស្រី អ៊ិច សុគន្ធា ក្នុងអាយុ៦៤ឆ្នាំ តាមការពិធីនៃព្រះពុទ្ធសាសនាដោយព្រះសង្ឃ២អង្គនិមន្តមកពីវត្តថ្មីនៅមិនឆ្ងាយប៉ុន្មានពី



គេហដ្ឋានឌីម៉ង់នោះទេ ។ ឌីម៉ង នឹង អ្នកស្រីមុំ មានកូន៣នាក់ ម្នាក់ចូលរៀនមហាវិទ្យាល័យ ហើយនៅ២នាក់ទៀត នៅកំរិតវិទ្យាល័យនៅឡើយទាំងពីរនាក់ប្ដីប្រពន្ធធ្វើការទាំងអស់គ្នា មានផ្ទះសម្បែង និងគ្រឿងប្រើប្រាស់ក្នុងផ្ទះសមរម្យយ៉ាងប្រសើរ ។ **តទៅទំព័រទី ១៨**



## សុខភាពល្អប្រសើរក្លូវដៃលោកអ្នក

បើលោកអ្នកមានជំងឺ ឈឺហើមជើងដៃពិបាកធ្វើចលនា -ឈឺនោមច្រើន -ដេកស្រមុំកខ្លាំង -មានស្ករច្រើនក្នុងឈាម -ឡើងទម្ងន់ធាត់ -ស្បែកឡើងកន្ទួល លោកអ្នកត្រូវចាំថា មានឱសថសក្តិសិទ្ធមានលក្ខណៈជាប្រភេទចំណី អាចជួយឱ្យសះស្បើយបានយ៉ាងឆាប់រហ័ស ។ ឱសថធម្មជាតិ ជាប្រេងចម្រាញ់ចេញពីពន្លកគ្រាប់ស្រូវមានការត្រួតពិនិត្យដោយវេជ្ជបណ្ឌិតត្រឹមត្រូវ អាចប្រើដោយមិនប្រឆាំងនឹងថ្នាំពេទ្យ ដែលប្រើប្រាស់រាល់ថ្ងៃទេ ។

លោក វិចិត្រ ភូស៊ីវុឌ ៦២ឆ្នាំ មុនប្រើ"អេមស្តា" ពាត់ឈឺទឹក នោមផ្អែម ឈឺបេះដូង លើសឈាម -"អាលើជី"-ឈឺសន្លាក់ ដៃជើង ឈឺក្រពះ...។ល។

**បន្ទាប់ពីបានប្រើ"អេមស្តា"**

លេប៩គ្រាប់ក្នុង១ថ្ងៃ-បីថ្ងៃក្រោយមក អន់ឈឺសន្លាក់ដៃជើង -១ខែក្រោយអាចរត់ឡើងជណ្ដើរបាន-បីខែក្រោយទៀតសរសៃឈាម២លែងស្ទះ-ឥឡូវនេះអាចរត់បាន១០គីឡូម៉ែត្រ-ធ្វើតេស្តឈាមមានភាពហ្នឹងនំល្អឡើងវិញ។





**ចង់ដឹងបន្ថែមលេខទូរស័ព្ទលេខ**
-ហ្វីឡាខាងត្បូង ២១៥ ២៣៧ ៥៧០៩ សាមន់ថា
-ហ្វីឡាខាងជើង ២១៥ ៦៦៧ ៨៤៣១ រ៉េរ



BUY RITE Pharmacy

Nhà Thuốc Tây 藥房 ឱសថស្ថាន

267-297-5879

ឱសថស្ថាន ថាច់ សូមស្វាគមន៍

• ឱសថការី ដាន់ ថាច់ មានសេចក្ដី រីករាយ និងបំរើសុខភាពបងប្អូន ក្នុងសហគមន៍ឱ្យបានប្រសើរ ។




1st PRIZE Samsung 32" LED HDTV

2nd PRIZE Samsung 32" LCD HDTV

3rd PRIZE Sony Playstation 3

• ភ្ញៀវដែលមកទិញថ្នាំតាមវេជ្ជបញ្ជាទាំងថ្មីទាំងចាស់ អាចនឹងត្រូវឆ្នោតទទួលរង្វាន់ ដូចរូបខាងក្រោម ថ្ងៃទី៣១ ខែធ្នូ ២០១២

• យើងជូនកូប៉េយដូចអ្នកឯទៀត

• ចុះថ្លៃពិសេសជូនព្រឹទ្ធាចារ្យ ។

• ផ្ញើថ្នាំជូនដល់ផ្ទះដោយឥតគិតថ្លៃ • ទទួលអ៊ិនសួរិនស្ទើរគ្រប់មុខ • ទទួលបន្តផ្ដល់ថ្នាំដែលលោកអ្នកកំពុងប្រើ ទិញមកពីឱសថស្ថានផ្សេងៗ

• តម្លៃថោកៗបំផុត និងមានស្តុកឱសថគ្រប់មុខប្រភេទ • ផ្ដល់សេវាដោយរហ័សទាន់ចិត្ត

• មានឱសថវីតាមីន-ឱសថចិនសែ និងឧបករណ៍ព្យាបាលមុខជំងឺ

**1337 W.Rockland St.Philadelphia, PA 19141(Corner of Old York Rd & Rockland St.)**

**Tel: 267-297-5879 Fax: 267-297-5880**



Angkor Restaurant

Ben city Plaza

# ភោជនីយដ្ឋាន អង្គរ

Angkor Restaurant



5520 Whitaker Ave, Unit 7 Philadelphia, Pa 19124 Phone: 215.831.1016

អាចបញ្ជាឲ្យធ្វើម្ហូបគ្រៅ "មេញ" បានមានម្ហូប អាមេរិកាំង ម្ហូបអាស៊ី ជាដើម

មានធ្វើម្ហូប VG សម្រាប់ អ្នកមិនពិសាសាច់

## ភោជនីយដ្ឋាន ម្ហូបខ្មែរ ទើបបើកថ្មី !

### នៅហ្វីឡាដែលហៀងខាងជើង

សូមអញ្ជើញមកពិសារម្ហូបខ្មែរគ្រប់មុខ ចំអិនដោយចុងភៅខ្មែរស្ទាត់ជំនាញ នាភោជនីយដ្ឋានធំទូលាយ បំរើម្ហូបខ្មែរពិតប្រាកដដ៏ឈ្ងុយឆ្ងាញ់ អ្នកបំរើភ្ញៀវរួសរាយ **មានកន្លែងចតរថយន្តគ្រប់គ្រាន់ !**



# ដល់ពេលអ្នកមាន និងអ្នកក្រត្រូវជួយគ្នាទៅវិញទៅមកហើយដើម្បីដោះស្រាយបញ្ហាស្រុក

ដោយ : គឹម សុស


គឹម សុស

នៅប្រទេសខ្មែរចំនួនប្រាក់ដែលរកបានរបស់ម្នាក់ៗចេះតែឃ្លាតពីគ្នាឆ្ងាយទៅៗ ហើយលឿនឡើងៗ។ នេះបើតាមតាមការស្រាវជ្រាវនៃក្រុមអ្នកប្រាជ្ញអាល្លឺម៉ង់ឈ្មោះ បៀតែលស្មាន់ស្ទិហ្វថង់ (German think tank Bertelsmann Stiftung) ចុះនៅភ្នំពេញប៉ុស្តិ៍ (Phnom Penh Post) នៅថ្ងៃទី២៤ខែកញ្ញាឆ្នាំ២០១២។

និយាយឱ្យខ្លីនេះមានន័យថា អ្នកមានកាន់តែមានឡើងមានឡើង។ ហើយអ្នកក្រកាន់តែក្រទៅក្រទៅ។

ហើយនេះជាសញ្ញាមួយទាយថា នៅស្រុកខ្មែរទៅមុខទៅដំណើរនៃការលូតលាស់ចម្រុងចម្រើនរបស់សង្គមខ្មែរអាចប្រទះនឹងការលំបាកឬឧបសគ្គដែលបណ្ដាលឱ្យសង្គមបែកបាក់ ធ្លាក់ចុះដុនដាបវេទនាដល់ទៅជាមានអំពើហិង្សាដែលអាចធ្លាក់ទៅជាការបង្ហូរឈាមរវាងគ្នា និងគ្នាបាន។

ហេតុអ្វី? ហេតុអ្វីបានជាភាពក្រ និងភាពមានឃ្លាតឆ្ងាយពីគ្នាធ្វើឱ្យមានការលំបាកឬឧបសគ្គនោះ។ យើងចាំឬដឹងទេថា មួយភាគនៃមូលហេតុដែលបណ្ណាលឱ្យរបបខ្មែរក្រហមកើតឡើងបាននៅប្រទេសខ្មែរនៅរវាងឆ្នាំ១៩៧៥និងឆ្នាំ១៩៧៩ ហើយឱ្យមានអំពើហិង្សាបង្ហូឈាមនៅប្រទេសអេហ្ស៊ីប (Egypt) ប្រទេសទុយនីស៊ីយ៉ា (Tunisia) និងប្រទេសលីប៊ីយ៉ា (Libya) ហើយនិងកំពុងឱ្យមានការបង្ហូរឈាមនៅប្រទេសស៊ីរីយ៉ា (Syria) ឥឡូវនេះមកពីដោយសារភាពក្រីក្រ។




អ្នកក្រគ្មានផ្ទះគ្មានការងារធ្វើ
គ្មានម្ហូបប្រចាំថ្ងៃ

តាមពិតធនធានឃ្លាតឆ្ងាយពីគ្នាមិនសុទ្ធតែបណ្ដាលឱ្យមានរឿងលំបាកឬឧបសគ្គនោះទេ បើចំនួនអ្នកមានច្រើនជាងចំនួនអ្នកក្រឬក៏ចំនួនអ្នកមានគ្រាន់តែច្រើនមិនរហូតដល់ទៅច្រើនជាងនោះក៏ដោយ។ ព្រោះថាធនធានរបស់អ្នកមាននោះនឹងធ្លាក់ទៅដល់អ្នកក្រតាមរបៀបណាមួយមិនខាន។ ឧទាហរណ៍ អ្នកមានអាចបង្កើតការងារឱ្យអ្នកក្រធ្វើ។ តាមពិតចំនួនអ្នកមានច្រើនតែងតែជួយប្រទេសឱ្យចម្រើនទៅមុខនិងឱ្យសប្បាយជាដើម។

ប៉ុន្តែរឿងធំវានៅក្នុងលក្ខណៈដែលមានចំនួនអ្នកក្រច្រើនជាងចំនួនអ្នកមានលើសលប់ពេក។

សព្វថ្ងៃនេះ តាមការស្រាវជ្រាវរបស់ក្រុមអ្នកប្រាជ្ញអាល្លឺម៉ង់នោះ នៅប្រទេសខ្មែរចំនួនអ្នកមានមិនសូវរីកចម្រើនទេ ប៉ុន្តែធនធានរបស់អ្នកមានរីកចម្រើនច្រើនហើយលឿនយ៉ាងរហ័ស មានន័យថាអ្នកមានកាន់តែមានឡើងៗ ហើយលឿនឡើងទៀតផង ។ នេះគឺជាសញ្ញាមួយដែលឱ្យតម្រុយថាចំនួនអ្នកក្រអាចទៅជាច្រើនជាងចំនួនអ្នកមានពេក។

ចំណែកអ្នកក្រវិញ ចំនួនបានថយបន្តិចដែរតែយឺត តាមពិតទោះជាតម្រុយនោះបង្ហាញយ៉ាងនោះក៏ដោយ។ នៅឆ្នាំ១៩៩៧ខ្មែរចំនួន៣៧ភាគរយនៃប្រជាពលរដ្ឋទាំងអស់រស់នៅក្រោមបន្ទាត់ភាពក្រីក្រមកដល់ឆ្នាំ២០០៧ចំនួននោះធ្លាក់មកនៅ៣១ភាគរយ។ ក្នុងរវាង១០ឆ្នាំចំនួនអ្នកក្រចុះបាន៦ភាគរយ ដូច្នេះឃើញថាចុះបានតិច។

ហើយចំពោះធនធានវិញក៏មានការកើនបន្តិចដែរប៉ុន្តែយឺត។ ក្នុងចំនួន១០ឆ្នាំកន្លងមកនេះសេដ្ឋកិច្ចខ្មែរបានឡើងជាមធ្យមពីជាង៦ភាគរយទៅជិត៨ភាគរយ។ បើគិតជាទឹកប្រាក់នៃផលិតផលក្នុងស្រុករួមរបស់មនុស្សម្នាក់ៗជាភាសាអង្គ្លេសហៅ ថា Gross Domestic Product per capita (GDP per capita) នៅឆ្នាំ១៩៩៦ម្នាក់ៗបាន៣៥០ដុល្លារសហរដ្ឋអាមេរិក ហើយនៅឆ្នាំ២០១១ម្នាក់ៗបាន៩១២ដុល្លាសហរដ្ឋអាមេរិក នេះបើតាមតួលេខរបស់ធនាគារពិភពលោក(World Bank or WB) និងធនាគារអភិវឌ្ឍន៍អាស៊ី(Asian Development Bank or ADB)។ ចំពោះប្រទេសកំពុងងើបឡើងពីភាពដុនដាប ឬប្រទេសដែលគេហៅថា ប្រទេសកំពុងអភិវឌ្ឍន៍ ហើយចាប់ផ្ដើមពីជិតសូន្យនោះ ការកើនឡើងខាងផ្នែកសេដ្ឋកិច្ចត្រឹមតែ៧ឬ៨ភាគរយប៉ុណ្ណោះមិនច្រើនទេ។ ធម្មតាចំពោះប្រទេសកំពុងអភិវឌ្ឍន៍ហើយចាប់ពីថ្នាក់ទាបយ៉ាងនោះ ការកើនខាងផ្នែក

តទៅទំព័រទី ១៣


## ក្រុមហ៊ុនទេសចរណ៍

- បំរើលោកអ្នកដោយគ្រប់ក្រុមហ៊ុនអាកាសចរណ៍ សំរាប់ដំណើរហើរក្នុងនិងក្រៅស្រុក
- ជួយរកអ្នកនាំផ្លូវជូនដំណើរទស្សនកិច្ចធ្វើការ
- ពន្យាលិខិតឆ្លងដែនខ្មែរ
- ធ្វើលិខិតអន្តោប្រវេសន៍
- ធ្វើទិដ្ឋាការសំរាប់ទេសចរណ៍
- ផ្ញើប្រាក់ប្រថាប់ត្រាបញ្ជាក់លើលិខិតជាផ្លូវការ

CENTURY TRAVEL & SERVICE CENTER
904 South 8th Street. Philadelphia, PA 19147
Tel : 215-625-2889; Cell : 267-934-9888

## ខ្មែរជួសជុលរថយន្ត
## KHMER AUTO REPAIR

CAR INSPECTION, DIAGNOTIC & REPAIR

ត្រួតពិនិត្យរថយន្តបញ្ជូរ
- ឆែករកកន្លែងខូចខាត និងជួសជុល
- យើងធ្វើហ្វ្រាំង ឬប្រេក
- ត្រួតពិនិត្យធ្វើម៉ាស៊ីនឱ្យស្រួលឡើងវិញ
- បញ្ចេះឡានអាល់ទេណាទ័រ
- បូមចរន្តទឹកវេឌីណាទ័រ
- សេវាត្រង់បីស្យង
- មើលតម្រងទ្រនាប់ និងពីញ្ញង

Brake Service
Turn up electronic
Starters Alternators
Radiators water pumps
Transmission Service
Struts checked & serviced
CV Joints Rack & Pinion
Shocks checked & Replace

115 West. Tabor Rd, Philadelphia, PA 19120
Tel: (215) 455-1422/Pat: 215-939-5634

## MARCOTTE LAW FIRM
## ក្រុមហ៊ុនមេធាវី Marcotte

45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229

- សេចក្ដីគ្រោះថ្នាក់ដល់រូបរាងកាយ
- ពិការភាពដោយសន្តិសុខសង្គម
- គ្រោះថ្នាក់ចរាចរណ៍
- បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
- គ្រោះថ្នាក់នៅការដ្ឋាន
- ច្បាប់គ្រួសារ និងលែងប្ដីប្រពន្ធ
- បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍

- Personal Injury
- Family Law & Divorce
- Disability
- Traffic Accidents
- Sex & Drug Crimes, OUI
- Work Accidents

មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទមកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ

(978) 458-1229

www.marcottelawfirm.com

# គណៈកម្មាធិការព្រំដែនកម្ពុជា

សមាគម មិនជាប់ពាក់ព័ន្ធ នឹង គណៈបក្ស នយោបាយ

Comité des Frontières du Cambodge ( C F C ) | Cambodia's Border Committee ( C B C )

ASSOCIATION NON APPARENTEE AU PARTI POLITIQUE ASSOCIATION UNAFFILIATED TO A POLITICAL PARTY

## គណកម្មាធិការព្រំដែនកម្ពុជាប្រទេសបារាំង និងក្នុងពិភពលោក

បារីសថ្ងៃទី ២០ តុលា ឆ្នាំ២០១២

## ផលវិបាកនៃសន្ធិសញ្ញាដែលបានចុះជាមួយប្រទេសវៀតណាម

ក្នុងឆ្នាំ១៩៧៩-១៩៨២-១៩៨៣-១៩៨៥-២០០៥



សៀន ប៉េងសែ

### ក/ សន្ធិសញ្ញាចុះថ្ងៃទី ១៨ កុម្ភៈ ១៩៧៩ (តពីលេខមុន)

នេះទៅវិញដែលដោយប្រត្យក្សមិនមានសភាព "អព្យាក្រឹត"នោះឡើយ ។

គឺការបូកបញ្ចូលគ្នាដោយគ្មានសមហេតុផល និងអាក្រក់គួរឱ្យស្អប់ខ្ពើមនេះហើយ ដែលជាប្រភពនាំឱ្យមានជម្លោះដ៏ច្រើន (និងការតវ៉ាដោយត្រឹមត្រូវពីខ្មែរ) ក្នុងពេលកំណត់ព្រំដែនលើទីកន្លែងដោយហេតុថា ការធ្វើរបៀបនេះ មិនដែលធ្វើឱ្យប្រទេសកម្ពុជាបានចំណេញទឹកដីអ្វីតែមួយចំណិតពីយួននោះឡើយ ផ្ទុយទៅវិញគឺប្រទេសវៀតណាមទេ ដែលកាត់យកទឹកដីខ្មែរទៅជាសម្បត្តិរបស់គេគ្រប់វេលាណាដែលបន្ទាត់ព្រំដែនតាមផែនទីខ្នាត ១/៥០ ០០០ នេះផ្តល់ [១(១)] ផែនទីរបស់យួនត្រូវបានរៀបចំឡើងរវាងឆ្នាំ ១៩៦០ និង១៩៧០ ឯផែនទីអាមេរិកាំងរៀបចំដោយកងទ័ពសហរដ្ឋអាមេរិក រវាងឆ្នាំ១៩៦២ និង១៩៧០ ក្នុងពេលសង្គ្រាមវៀតណាម ។

អត្ថប្រយោជន៍ដល់គេ ។ ក្នុងពេលឥឡូវនេះទៀត លោក ហ៊ុន សែន ថែមទាំងកំពុងគិតពីការកែប្រែរដ្ឋធម្មនុញ្ញខ្មែរថែមទៀតផង ដើម្បីបញ្ជាក់ឱ្យច្បាស់ពីអត្ថប្រយោជន៍របស់យួន ។ ចំពោះផ្ទៃដីរបស់ប្រទេសកម្ពុជាវិញ លោក ហ៊ុន សែន បានច្រានចោលកំណត់ ១៨១ ០៣៥ គម² តែលោកនេះឥតបាននិយាយថា តើលោកបានយកផែនទីភូមិសាស្ត្រណាមួយយកមកប្រើនោះទេ ដើម្បីឱ្យបានទំហំដែលត្រឹមត្រូវពិតប្រាកដ តើតាមនិយាមកាណា និងតើមានផ្ទៃដីចំនួនប៉ុន្មានគីឡូម៉ែត្រក្រឡាមានភូមិខ្មែរចំនួនប៉ុន្មានត្រួតលើគ្នាជាមួយនឹងទឹកដី ឬភូមិយួន និងផ្ទុយទៅវិញ តើខាងយួនវិញ មានប៉ុន្មានដែរ ដែលត្រួតលើទឹកដីខ្មែរ និងភូមិខ្មែរ ។ រហូតមកដល់សព្វថ្ងៃនេះ លោក ហ៊ុន សែន ពុំដែលបានបង្ហាញទីភូមិសាស្ត្រថ្មីរបស់លោក ដល់សាធារណជនម្តងណានោះឡើយ សូម្បីតែភាគខ្លះៗ ប្រហែលៗក៏គ្មានផង ប៉ុន្តែលោកបាននិយាយថា ទៅតាមឧបករណ៍ទំនើប និងយ៉ាងវិសេសរបស់លោក "ផ្ទៃដីប្រទេសកម្ពុជាមានទំហំ ១៨១ ៣៣៥ គម² គឺ ៣០០គម² លើសពីពេលមុន ដោយឥតមានកាត់ពីវៀតណាមនោះទេ" ដោយឥតបញ្ជាក់ដរាប ថាតើដីនេះ បានមកពីណាដោយរបៀបណានោះឡើយ ។

ធ្វើយ៉ាងដូច្នេះលោកចង់អះអាងថា យ៉ាងដូម្តេច?ក៏ថាបានដែរ ។ ប្រសើរជាងនេះទៅទៀតកាលខែវិច្ឆិកា ឆ្នាំ ២០០៥ លោក ហ៊ុន សែន បានថ្លែងដោយស្ងួតថា "សន្ធិសញ្ញាបំពេញបន្ថែមរបស់លោកដែលព្រះករុណា សីហមុនី នឹងចុះសច្ចាប័ននោះ"បាន ធ្វើឱ្យប្រទេសកម្ពុជា

[២(២)] គង់ សុថារិទ្ធិ "ព្រះករុណានឹងចុះហត្ថលេខានៅថ្ងៃនេះ តាមលោក ហ៊ុន សែន ។ កាសែតកំបូជស្វារ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ២០០៥ ។

ចំណេញទឹកដី និងផ្ទៃទឹកទន្លេជាច្រើនពាន់គីឡូម៉ែត្រ [២(២)] ។ ជាការប្រាកដគ្មាននរណាម្នាក់គេជឿលើការអះអាងនេះនោះឡើយ ។

នៅទីបំផុតអ្វីដែលធ្ងន់ធ្ងរនោះ គឺសូម្បីគ្រាន់ជាគណៈកម្មការចំរុះ (ឆ្នាំ១៩៩៩) គណៈកម្មការនេះហ៊ានរហូតទទួលស្គាល់ជាសាធារណៈនូវសុពលភាពនៃគ្រប់សិទ្ធិសញ្ញាទាំងអស់ដែលបានចុះហត្ថលេខារួចមកហើយ រវាងប្រទេសវៀតណាមបានបោះរួចមក ហើយជាឯកតោភាគីក្នុងឆ្នាំ១៩៨៤,១៩៨៦, និង១៩៨៨ ។

គណៈរដ្ឋមន្ត្រីក្រោមអធិបតីភាព លោក ហ៊ុន សែន នៅថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ២០០០ បានទទួលស្គាល់ដោយគណៈកម្មការចំរុះនេះ ។ ទង្វើនេះហើយដែលបានបើកផ្លូវដល់លោក ហ៊ុន សែន ឆ្ពោះទៅដល់ការចុះហត្ថលេខាលើសិទ្ធិសញ្ញាបំពេញបន្ថែមជាមួយប្រទេសវៀតណាម ។ បន្ថែមទោះបីយ៉ាងនេះក៏ដោយលោក ហ៊ុន សែន ពុំអាចចុះហត្ថលេខាលើសិទ្ធិសញ្ញានេះ ឱ្យបានទាន់ពេលវេលាដែលបានគ្រោងទុកនោះឡើយ ដោយហេតុមានបាតុកម្មប្រឆាំងជាច្រើនពីសំណាក់និស្សិត និងក្រុមសង្គមស៊ីវិលទាំងក្នុង និងក្រៅប្រទេសកម្ពុជាក្នុងនោះមានគណកម្មាធិការព្រំដែនកម្ពុជាផង ។

### ង-សន្ធិសញ្ញាបំពេញបន្ថែមថ្ងៃទី ១០ តុលា ២០០៥

នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៥ លោក ហ៊ុន សែន បានចោទប្រកាន់ពី "ការរំលោភផ្សេងៗ

(មានតនៅលេខក្រោយ)


# GATEWAY FAMILY DENTAL

NOW OPENED AT GATEWAY CENTER II (978) 455-5044

151 WARREN STREET, SUITE 120 LOWELL, MA 01852 (Same building as Social Security/near the courthouse)



**DR. SERENA B. CHUOP**

Dr. Serena B. Chuop was born in Cambodia. She received her Bachelor of Science from Boston University and went on to graduate from Boston University Goldman School of Dental Medicine in the year 2000. For over 10 years, she has been in private practices providing all aspects of General Dentistry. Dr. Chuop has opened a brand new state of the art dental practice that includes digital x-ray, paperless patient chart system, and brand new dental equipments.




**WE PROVIDE ALL SERVICES INCLUDING: យើងផ្តល់នូវសេវាដូចខាងក្រោមនេះ**

- CLEANING
- FILLINGS
- BONDINGS
- COSMETIC DENTISTRY
- CROWNS/BRIDGES
- DENTURES
- IMPLANTS
- EXTRACTIONS
- TEETH WHITENING
- VENEERS
- EMERGENCY DENTAL TREATMENT
- ROOT CANAL TREATMENT
- DENTAL SERVICES TO CHILDREN

- សំអាតធ្មេញ
- បំពេញធ្មេញប្រហោង
- ថ្នាំសំរាប់ការពារធ្មេញ
- ធ្មេញពាក់ជុំនួសធ្មេញដែលបាក់
- ក្រាសធ្មេញពាក់
- ដាំធ្មេញតាមរន្ធធ្មេញចាស់
- ដកធ្មេញ
- ធ្វើធ្មេញឱ្យសស្អាត
- វែរនីស្រោបធ្មេញ
- ព្យាបាល និងការពារធ្មេញជាទៀងទាត់
- ព្យាបាល ឫសថ្គាមធ្មេញ
- សេវាព្យាបាលសំរាប់កុមារ

www.gatewayfamilydental.com

MOST DENTAL INSURANCES ACCEPTED
INCLUDING MASSHEALTH FOR KIDS
FINANCING AVALIABLE
យើងទទួលនូវគ្រប់ អ៊ិន ស៊ូរិន
Masshealth for Kids
យើងសំរួលការបង់ថ្លៃព្យាបាលប្រចាំខែ
CALL FOR YOUR FREE CONSULTATION
(978) 455-5044

ឌឺ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឺ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ អង្គារ៍ ទី២០ ខែវិច្ឆិកា ឆ្នាំ២០១២

# លោក អូបាម៉ា ជំរុញឱ្យលោក ហ៊ុន សែន យកចិត្តទុកដាក់អំពីបញ្ហាសិទ្ធិមនុស្សនៅកម្ពុជា

**គុជ ណារ៉ែនឌិង Zsombor Peter**

ប្រធានាធិបតីអាមេរិកលោក បារ៉ាក អូបាម៉ា (Barack Obama) បានជំរុញឱ្យលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន យកចិត្តទុកដាក់ពីបញ្ហាសិទ្ធិមនុស្សអំឡុងកិច្ចប្រជុំសម្ងាត់មួយរវាងមេដឹកនាំទាំងពីរនៅក្នុងរាជធានីភ្នំពេញ កាលពីទី១៩ខែវិច្ឆិកា ឆ្នាំ២០១២ដោយអំពាវនាវឱ្យមានការបោះឆ្នោតដោយយុត្តិធម៌ និងឱ្យមានការដោះលែងអ្នកនយោបាយ។

យោងតាមទីភ្នាក់ងារព័ត៌មានរ៉យទ័រ បានឱ្យដឹងថា ក្នុងការបំពេញទស្សកិច្ចលើកដំបូងមក នេះ អង្គការសិទ្ធិមនុស្សនានារួមជាមួយសមាជិកសភាអូស្ត្រាលី អឺរ៉ុប និងសហរដ្ឋអាមេរិក បានសុំឱ្យលោក អូបាម៉ា ជួយជំរុញលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ឱ្យដោះស្រាយបញ្ហាសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា ដែលកំពុងធ្លាក់ចុះ ។ លិខិតផ្ញើជូនលោកប្រធានាធិបតីពីសំណាក់សមាជិកសភាសហរដ្ឋអាមេរិកមួយចំនួន បានអំពាវនាវសុំឱ្យលោក អូបាម៉ា លើកយកបញ្ហាដូចជាការផ្តន្ទាទោសតាមបែបនយោបាយ វិបត្តិក្នុងប្រព័ន្ធបោះឆ្នោត ការចាប់យកដី និងការបណ្តេញប្រជាពលរដ្ឋចេញពីលំនៅដ្ឋាន។



កាន់ប្រទេសកម្ពុជារបស់លោកប្រធានាធិបតី អាមេរិកក្នុងតំណែង លោក បេន រ៉ូដ (Ben Rhodes) ទីប្រឹក្សារងផ្នែកសន្តិសុខជាតិរបស់អាមេរិក បានថ្លែងថា លោក អូបាម៉ា បានជួបប្រជុំជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដោយលើកឡើងពីបញ្ហាសិទ្ធិមនុស្ស។

សំដៅដល់ការពិភាក្សារវាងមេដឹកនាំទាំងពីរ លោក បេន រ៉ូដ មានប្រសាសន៍ថា "ត្រង់ចំណុចនេះ ខ្ញុំចង់និយាយថា ចាំបាច់ឱ្យមានការបោះឆ្នោតដោយសេរី និងយុត្តិធម៌ និងត្រូវមានគណៈកម្មាធិការបោះឆ្នោតនោះ ព្រមទាំងត្រូវដោះលែងអ្នកទោសនយោបាយ និងឱ្យគណបក្សប្រឆាំងអាចចូលធ្វើសកម្មភាពបាន"។

យោងតាមរ៉យទ័របានឱ្យដឹងថា លោក បេន រ៉ូដ បន្ថែមថា លោក អូបាម៉ា ក៏បានប្រាប់លោក ហ៊ុន សែន ថា កម្ពុជាត្រូវបន្តដោះស្រាយបញ្ហានេះ ហើយបានយល់ស្របថា កិច្ចប្រជុំនេះអាចចាត់ទុកថា មាន "ភាពតានតឹង"។

លោក អូបាម៉ា អញ្ជើញមកដល់ប្រទេសកម្ពុជាកាលពីរសៀលថ្ងៃទី១៩ខែវិច្ឆិកា ឆ្នាំ២០១២ ដោយដំណើរពីប្រទេសភូមា ក្នុងដំណើរទស្សនកិច្ចនៅទូទាំងតំបន់អាស៊ីភាគអាគ្នេយ៍ ដើម្បីជំរុញផែនការរបស់អាមេរិកក្នុងការបង្កើនទំនាក់ទំនងផ្នែកយោធា ផ្នែកការទូត និងសេដ្ឋកិច្ចនៅក្នុងតំបន់ ដើម្បីធ្វើឱ្យមានតុល្យភាពអំណាចជាមួយនិងចិន ដែលកំពុងតែមានឥទ្ធិពលមកលើតំបន់នេះ។

ប៉ុន្មានសប្តាហ៍មុនការអញ្ជើញមកទស្សនកិច្ច

លោក ប្រាក់ សុខុន រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រីបានមានប្រសាសន៍ថា លោក អូបាម៉ា គ្រាន់តែលើកយកអំពីបញ្ហាសិទ្ធិមនុស្សតាមការស្នើឡើងដោយសមាជិកសហរដ្ឋអាមេរិកប៉ុណ្ណោះ។

លោក សុខុន បានមានប្រសាសន៍ថា លោក ហ៊ុន សែន បានអរគុណចំពោះលោកប្រធានាធិបតីចំពោះ "ការនិយាយដ៏ស្មោះត្រង់" របស់លោក ប៉ុន្តែលោកបានបន្តថា លោកគឺជាជនរងគ្រោះ "នៃយុទ្ធនាការមួលបង្កាច់ខុសពីការពិតពាក់ព័ន្ធនឹងស្ថានភាពសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា"។

លោកក៏បានមានប្រសាសន៍ផងដែរថា អំឡុងពេលឆ្លើយឆ្លងដោយស្មោះត្រង់ លោកនាយករដ្ឋមន្ត្រីនៅតែអះអាងថា កម្ពុជានៅតែមានកំណត់ត្រាសិទ្ធិមនុស្សប្រសើរជាងប្រទេសមួយចំនួននៅសហគមន៍អាស៊ាន។

លោក សុខុន បានប្រាប់អ្នកយកព័ត៌មានថា "តាមរយៈយុទ្ធនាការវាយមួលបង្កាច់ខុសពីការពិតនេះ ប្រទេសកម្ពុជាហាក់បីដូចជាសិស្សខូចម្នាក់ អន់ជាងភូមាទៅទៀត ដែលត្រូវសុំឱ្យជួយភូមា ដូច្នេះភូមាក៏ជាមនុស្សខូចដែរ"។

លោក សុខុន បានបន្តថា "ដូច្នេះលោកនាយករដ្ឋមន្ត្រីបានឆ្លៀតឱកាសយកកិច្ចប្រជុំរយៈពេលខ្លីនេះ ដើម្បីផ្តល់ព័ត៌មានឱ្យលោក អូបាម៉ា បានជ្រាបថា ស្ថានភាពសិទ្ធិមនុស្សជាពិសេសសេរីភាពខាងនយោបាយនៅក្នុងប្រទេសកម្ពុជា មិនអាក្រក់ដូច

តទៅទំព័រទី១៩

## Obama Presses Hun Sen on Human Rights Record

**The Cambodia Daily**

U.S President Barack Obama pressed Prime MInistrer Hun Sen on the government´s human rights record during the closed-door meeting between the two leaders in Phnom Penh yesterday, calling for fair elections and the release of all political prisoners.

In the first visit to Cambodia by the serving American president, U.S. deputy national security adviser Ben Rhodes said Mr. Obama devoted his entire meeting with the prime minister to Human Rights issues, according to Reuters.

"In particular, I would say the need for them to move toward elections that are fair and free, the need for an independent election commission associated with those election, the need to allow for the release of political prisoners and for opposition parties to be able to operate," Mr. Rhodes said, referring to the discussion between the two leaders.

Mr. Rhodes added that Mr. Obama a;so told to Mr. Hun Sen that Cambodia had "much further to go on that set of issues," and agreed thath the meeting could be described as "tense," according to Reuters.

Mr. Obama arrived in Cambodia yesterday afternoon from Burma in a trip throgh South-east Asia to promote the U.S. plans to beef up its military, along with a diplomatic and economic "reblance" of the region in the face of a rising China.

In the weeks leading up to the visit, rights groups were jioned by lawmakers from Australia, Europe and the U.S. in raising the issue of the country's poor human right record.

A letter to the prisident from some of the most senior lawmakers in the U.S. called on Mr. Obama to raise everything from politically motivated convictions, a flawed electoral system, land graps and evictions with Mr. Hun Sen.

Speaking at a press conference after the meeting, Council of Ministers Secretary of state Prak Sohon said Mr. Obama had raised human rights in his talks, but only because he had been asked to do so by other U.S. lawmakers.

Mr. Hun Sen, he said, thanked the president for his "frank speech," but said he was the victime of "a campaign to slander the facts related to the human rights situation and democracy in Cambodia."

During the frank exchange, Mr. Hun Sen also insided that Cambodia Still had a better human rights record than some of its regional partners in Sean, Mr. Sokhon said.

"through a campaign of slander, it would seem as though Cambodia is a bad student, worse than Myanmar, that a teather that was asked to held Myanmar has become a bad person," Mr. Sokhon told reporters.

"So the prime minister took the opportunity of his short meeting to inform President Obama that the human rights situation, especially political freedom, in Cambodia is not that bad compares to human rights and political rights in neighboring countries."

"In our country, politics is wide open to all political parties and the opposition parties have the right to do anything in accrodance with the law," Mr.Sokhon continued.

Ahead of his visit, Mr, Obama was urges specifically to press Mr. Hun Sen on apardon for opposition leader Sam Rainsy, who is currently in self-imposed exile avoiding an 11-year jail sentence oncharges widely believed to be politically motivated.

Mr. Sokhon said the opposition leader's name did not come up in the talks with Mr. Obama.

"Samdech made it clear that in Cambodia there are not political prisoners just because there is a report and a protest demanding the release of all politicall\ prisoners," he said.

"Samdech said that there are no political prisoners in Cambodia, but that some politicians who break the law. So the politician must be prosecuted in accordance with the law."

He explained that Mr. Obama did raise the case of Mam Sonando, the popular radio station owner, who was sentenced to 20 years in jail last month on charges of leading a so-called insurrecton. those charges have also been widely condemned as politically motivated.

"Samdech explained that there was confusion that it was an attempt to shut down the station," Mr. Sokhon said "In fact the station is still operating and remains very popular with listeners. At the same time, Samdech stressed that is was an individual who faced the law because that individual committed wrongdoing, so that individual must face the law."

He said Mr. Hun Sen also told the U.S. president that the reports of mass evictions were overblown.

"Regarding land issues and forced evictions, Samdech acknowledged that there have been some because there were some people who moved onto land illegally, so it [the government] was forced to implement the law to remove them," he said, adding that Mr. Hun Sen had attempted to assure Mr. Obam that such cases were rare.

Rights groups have sigled out the government's land concessions to agribusiness and mining firms as the country's primier human rights issue, haveing affected some 400,000 people over the past decade.

Mr. Sohon said that the prime minister did raise at least one issue of his owner-- the more than $400 million with interest Cambodia still owes the U.S.dating back to the 1970s Lon Nol government.

He said Mr. Hun Sen repeated Cambodia's proposal that is pay back on 30 percent of the debt at 1 percent interest and agree to spend what is would have given the U.S. on education, demining and cultural projects.

The U.S. Embassy did not immediatly reply to a request for comment.

Mr. Obama is in Cambodia attending the Asean and East Asia summits and is scheduled to depart today for Japan.

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ អង្គារ៍ ទី២០ ខែវិច្ឆិកា ឆ្នាំ២០១២

## Manila, Phnompenh Dispute South China Sea Talks

**By Dene Here Chen**

**The Cambodiadaily**

Diplomatic tensions over contested temitory in the South China Sea mounted again yesterday with Philippine President Benigno Aquino contesting comments made by cambodia on Sunday that Asean states had unanimously sgreed not to "inter nationalize" the dispute whith china.

Speaking to reporters on Sunday at the Asean Summit in Phnompenh, Kao Kim Houn, Secretary of state for the ministry of foriegn Affairs, said that regional leaders had agreed that the sea issue would only be addressed through the so called Asean-China mechanism.

But during the Asean-Japan Summit yestersay, Mr.Aquino said that the Philippines had not agreed, as claimed, to aviod internationalizing the contentious issue of the South China Sea.

"At the Asean Retreat yesterday {Sunday}, various views were expressed on Asean unity which were translated by the Chair into an Asean consensus.This was not the understanding of both the Philippines and at least one other country," the Philippines said in a statement yesterday.

"When the chair in the Asean Japan meeting... Allusded to this, President Benigno Aquino III indicated that the Philippines was not in accord that while the Philippines was for Asean unit, It has the in herent right to defend its national interest when deemed necessary," the statement continued.

"Foreign Secretary Albert F. Del Risario had also confirmed the Philippine position in a formal letter to the Chair with copies furnished to call Asean Foreign Ministers," the statement added.

In an interview, Mr. Del Rosario yesterday flatly denied Mr. Kim Hourn´s comments on Asean´s aparent consensus not to internationalize the ispurte.

"No, no, we did not agree to that I think there was a misunderstanding," Mr.Del Rosario said before the that of the Asean-South Korean Summit. "I think there were views expressed on Asean unity and it was translated into a consensus that was not our understanding".

"We cleared that today {with Cambodia}," he added.

Despite Mr. Aquino reiterating the Philippines´ position during the Asean-Japan Summit, Mr Kim Hourn yesterday continued to stand by his original comments regarding a consensus.

"Yes, during the retreast of the Asean leadre, and at the suggestion of thr malaysian Prime Minister {Najib Razak} the leaders agreed not to internationalize the South China issue, and of course to address the issues through the existing China-Asean mechanism," Mr.Kim Hourn maintained.

However, Asean Secretary General Surin Pitsuwan confirmed the the Philippines had disagreed on his issue during Sunday´s meeting.

"The Philippines has reseved the right to use other forums... and channels, they said, to denfend their rights and their national interests," Mr Pitsuwan said in an interview on the sidelines of yesterday´s meeting.

"{T} the issue is rather contentious so, there are different interprestions, but we are working in the same direction trying to resolve the problem."

The new verbal spat between PhnomPenh and Manila follows a major breakdown in talks at the last Asean Summit in Phnom Penh in July where Cambodia, in its role as chair, did everything possible to keep the teritorial dispute off the agenda. The decision meant that the 10menber bloc failed to release a final joint communiqué for the first time in its 45-year history.

The maritime dispute over the resource-rich body of the water pits four Asean countries the Philippines, vietnam, Malaysia and Brunei against China. As recently as April, navy and coast guard ships from China and the Philippines engaged in a standoff in the waters.

While the Asean claimant states prefer multilateral negotiation on the issue and hope for U.S in volvement Beijig has consistently called for bilateral discusions, which would give China more leverage in negotiations with individual Asean states.

Indonesias Foreign Minister Marty Nata;egawa, who has taken on the role of de facto mediator in the dispute said yesterday that he had written a letter to Philippines of ficials about the disagreement, as he believe both viewpionts do not cancel each other out.

"The two objectives are not actually mutually exclusive, and I have written formally to our Philippines colleague to affirm that actually their view is actually in sync with what has been said all this time that there is actually

**Continue to Page 14**

## រដ្ឋាភិបាលក្រុងម៉ានិល និងក្រុងភ្នំពេញខ្វែង គំនិតអំពីសមុទ្រចិនខាងត្បូង

**ខេមបូឌា ដេលី**

ភាពតានតឹងតាមរយៈការទូតអំពីបញ្ហាជម្លោះដែនទឹកក្នុងសមុទ្រចិនខាងត្បូងបានផ្ទុះឡើងម្តងទៀត កាលពីម្សិលមិញ ដោយសារប្រធានាធិបតីហ្វីលីពីន លោកបេនិកណូអាគីណូ(Benigno Aguino)បានជំទាស់ចំពោះសេចក្តីថ្លែងការណ៍របស់កម្ពុជាកាលពីថ្ងៃអាទិត្យដែលថា រដ្ឋជាសមាជិកអាស៊ានបានយល់ព្រមមិនដាក់បញ្ហាសមុទ្រចិនខាងត្បូងជាមួយប្រទេសចិន "ជារឿងអន្តរជាតិ"។

ថ្លែងទៅកាន់អ្នកយកព័ត៌មាន កាលពីថ្ងៃអាទិត្យនៅឯកិច្ចប្រជុំកំពូលអាស៊ានក្នុងរាជធានីភ្នំពេញ លោក កៅ គឹមហួន រដ្ឋលេខាធិការក្រសួងការបរទេសមានប្រសាសន៍ថា មេដឹកនាំនៅក្នុងតំបន់បានយល់ព្រមថា បញ្ហាជម្លោះក្នុងដែនសមុទ្រចិនខាងត្បូងគួរតែដោះស្រាយតាមរយៈយន្តការអាស៊ាន-ចិន ។

ប៉ុន្តែក្នុងអំឡុងកិច្ចប្រជុំកំពូលអាស៊ាន និងជប៉ុនលកាលពីប៉ុន្មានថ្ងៃមុន ប្រធានាធិបតីអាគីណូ មានប្រសាសន៍ថា ប្រទេសហ្វីលីពីន មិនបានយល់ព្រមដូច្នេះទេ ចំពោះការអះអាងថា គឺដើម្បីបញ្ហាចៀសវាងមិនឱ្យយកបញ្ហាក្នុងសមុទ្រចិនខាងត្បូង ធ្វើជាជម្លោះរបស់អន្តរជាតិ។

ប្រទេសហ្វីលីពីន បានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍មួយថា "នៅក្នុងកិច្ចប្រជុំកំពូលអាស៊ានក្រៅផ្លូវការកាលពីថ្ងៃអាទិត្យ មានការបញ្ចេញទស្សនៈផ្សេងៗគ្នា ជុំវិញសាមគ្គីភាពក្នុងសហគមន៍អាស៊ាន ដែលត្រូវបានប្រធានអាស៊ានបកប្រែថា ជាមតិរួមរបស់អាស៊ាន ។ បញ្ហានេះប្រទេសហ្វីលីពីន និងយ៉ាងហោចណាស់ ប្រទេសមួយផ្សេងទៀត មិនបានដឹងទេ"។

សេចក្តីថ្លែងការណ៍បានបន្ថែមទៀតថា "នៅពេលប្រធានកិច្ចប្រជុំកំពូលអាស៊ាន និងជប៉ុន... បានសង្ខេបបញ្ហានេះ លោកប្រធានាធិបតីបេនិកណូ អាគីណូបញ្ជាក់ថា ប្រទេសពីលីពីនមិនយល់ស្របនោះទេ ខណៈពេលពីលីពីនមានបុព្វសិទ្ធិដើម្បីការពារផលប្រយោជន៍ជាតិរបស់ខ្លួននៅពេលណាចាំបាច់"។

សេចក្តីថ្លែងការណ៍នោះបានបន្ថែមថា "រដ្ឋមន្ត្រីក្រសួងការបរទេស លោកអាល់បឺត ដែលរ៉ូសារីយ៉ូ គឺបានបញ្ជាក់រួចហើយអំពីជំហរបស់ប្រទេសហ្វីលីពីន នៅក្នុងលិខិតផ្លូវការណ៍ផ្ញើជូនប្រធានកិច្ចប្រជុំអាស៊ាននិងបានសំឡេងជូងដល់រដ្ឋមន្ត្រីការបរទេសអាស៊ានទាំងអស់"។

នៅក្នុងកិច្ចសម្ភាសន៍មួយលោកដែលរ៉ូសារីយ៉ូ បានច្រានចោលសេចក្តីអធិប្បាយរបស់លោកកៅ គឹមហួន ស្តីអំពីមតិរួមរបស់សមាជិកអាស៊ានដែលថា បានយល់ព្រមមិនយកជម្លោះក្នុងសមុទ្រចិនខាងត្បូងដាក់ជារឿងរបស់អន្តរជាតិនោះ។

លោកដែលរ៉ូសារីយ៉ូ បានថ្លែងនៅមុនពេលកិច្ចចាប់ផ្តើមប្រជុំកំពូលអាស៊ាននិងកូរ៉េខាងត្បូងថា "ទេទេ យើងមិនយល់ព្រមអ៊ីចឹងទេ។ យើងគិតថាមានការយល់ច្រឡំ។ ខ្ញុំគិតថា មានការបញ្ចេញទស្សនអំពីសាមគ្គីភាពក្នុងសហគមន៍អាស៊ាន ហើយត្រូវបានបកប្រែថា ជាមតិរួមដែលយើងមិនបានដឹងទេ។ យើងបានបកស្រាយប្រាប់ប្រទេសកម្ពុជាច្បាស់លាស់អស់ហើយ "។

ទោះបីលោកអាគីណូ បានបញ្ជាក់អំពីជំហរបស់ប្រទេសហ្វីលីពីន អំឡុងកិច្ចប្រជុំកំពូលអាស៊ាន ជប៉ុនក៏ដោយ ក៏លោកកៅ គឹមហួន កាលពីថ្ងៃអាទិត្យបានបន្តការពារជំហរបស់លោក ចំពោះការអះអាងនៅក្នុងសេចក្តីថ្លែងការណ៍រួមរបស់លោកដដែល។

លោកគឹមហួនបានបញ្ជាក់ថា "ពិតហើយក្នុងអំឡុងកិច្ចប្រជុំក្រៅផ្លូវការនៃមេដឹកនាំប្រទេសជាសមាជិកអាស៊ានទាំងអស់និងតាមរយៈសំណើររបស់លោកនាយករដ្ឋមន្ត្រីម៉ាឡេស៊ីណាជីត រ៉ាហ្សា (Najib R-zak) មេដឹកនាំទាំងអស់បានយល់ព្រមមិនដាក់បញ្ហាសមុទ្រចិនខាងត្បូងជាបញ្ហាអន្តរជាតិទេ ហើយកិច្ចប្រជុំលើកឡើងថា បញ្ហានេះគួរដោះស្រាយតាមរយៈយន្តការអាស៊ាន-ចិន ដែលមានស្រាប់"។

ទោះជាយ៉ាងណាលោកស៊ូរិនពិតស៊ូវ៉ាន់ (Surin Pitsuwan)អគ្គលេខាធិការអាស៊ានបានបញ្ជាក់ថា ប្រទេសហ្វីលីពីន មិនបានយល់ព្រមលើបញ្ហានេះទេ អំឡុងកិច្ចប្រជុំកាលពីថ្ងៃអាទិត្យ លោកពិត ស៊ូវណ្ណមានប្រសាសន៍ក្នុងបទសម្ភាសន៍មួយនៅក្រៅកិច្ចប្រជុំថា "ប្រទេសហ្វីលីពីនរក្សាសិទ្ធិប្រើប្រាស់វេទិកា ...និងតាមប្រព័ន្ធផ្សេងៗទៀតដែលពួកគេបានលើកឡើងថា ដើម្បីការពារសិទ្ធិនិងផលប្រយោជន៍ជាតិរបស់ពួកគេ"។

លោកថ្លែងបន្តថា "បញ្ហានេះគឺមិនមែន ជាបញ្ហាជម្លោះដែលមានការបកស្រាយទៅវិញនោះទេ ប៉ុន្តែយើងត្រូវធ្វើការជាមួយគ្នាក្នុងគោលបំណងដូចគ្នាដើម្បីដោះស្រាយបញ្ហា"។

ជម្លោះពាក្យសំដីថ្មីៗនេះរវាងរាជរដ្ឋាភិ បាលនិងរដ្ឋាភិបាលក្រុងម៉ានីលកើតឡើងបន្ទាប់ពីការបរាជ័យក្នុងការជជែក ពិភាក្សានៅអំឡុងកិច្ចប្រជុំកំពូលអាស៊ាននៅរាជធានីភ្នំពេញ កាលពីខែកក្កដា ដែលប្រទេសកម្ពុជា ជាប្រធានអាស៊ានបានព្យាយាមដាក់បញ្ហាដែនទឹកឱ្យស្ថិតនៅក្រៅរបៀបវីរៈនៃកិច្ចប្រជុំ។ ការសម្រេចចិត្តបែបនេះ បានធ្វើរដ្ឋជាសមាជិកអាស៊ានទាំង១០បរាជ័យមិនបានចេញ **តទៅទំព័រទី ១០**

តមកពីទំព័រទី ១

# មន្ត្រីជាន់ខ្ពស់គណបក្សសង្គ្រោះ...

និងបងប្អូនរួមជាតិដែលចង់ឱ្យគណបក្សជំទាស់ធំ២ គឺគណបក្សសមរង្ស៊ី និង គណបក្សសិទ្ធិមនុស្ស រួបរួមគ្នាបង្កើតទៅជាគណបក្សប្រជាធិបតេយ្យដ៏ធំ១។

ឥឡូវនេះគណបក្សដ៏ធំមានឈ្មោះថា"គណបក្សសង្គ្រោះជាតិ"បានបង្កើតឡើងដោយពេញច្បាប់ហើយ ដែលមានលោក សម រង្ស៊ី ជាប្រធាន ហើយនៅពេលឆាប់ៗខាងមុខ នឹងមានលោក កឹម សុខា ជាអនុប្រធាន។


កឹម សុខា និងសម រង្ស៊ី ចាប់ដៃគ្នាដើម្បីសង្គ្រោះជាតិ

ដូច្នេះហើយ បានជាគណកម្មាធិការប្រតិបត្តិនៃចលនាប្រជាធិបតេយ្យសង្គ្រោះជាតិ សាខាប្រចាំក្រុងហ្វី ឡាដែលហ្វីយ៉ា បានរៀបចំពិធីជប់លៀងទទួលស្វាគមន៍ ដែលមានបងប្អូនរួមជាតិប្រមាណជាង១រយនាក់ បានអញ្ជើញមកចូលរួម ដើម្បីស្តាប់សេចក្តីថ្លែងការណ៍ពីស្ថានភាពនយោបាយទូរទៅខ្មែរ ទាំងអស់រស់នៅក្នុងនិងក្រៅប្រទេសឱ្យស្ទុះងើបក្រោកឈរឡើង មកចូលរួបរួមគ្នាជាមួយគណបក្សសង្គ្រោះជាតិ ដើម្បីជួយស្រោចស្រង់សង្គ្រោះជាតិ មាតុភូមិខ្មែរយើង ដែលកំពុងតែស្ថិតនៅក្នុងអំណាចនៃមេដឹកនាំផ្តាច់ការអគតិអយុត្តិធម៌ បំផ្លេចបំផ្លាញសម្បត្តិជាតិ និងសម្បត្តិធម្មជាតិ ដ៏សម្បូរហូរហៀ ឥឡូវស្ទើរតែរលាយអស់រលីងពីប្រទេសយើងហើយ ។ ជាពិសេស បានបណ្តោយឱ្យបណ្តាប្រជាពលរដ្ឋធ្លាក់ក្នុងសភាពក្រីក្រលំបាកតោកយ៉ាកកាន់តែខ្លាំងឡើងៗ រីឯ






មន្ត្រីធំៗឧកញ៉ាធំៗក្រុមហ៊ុនធំៗទាំងខ្មែរទាំងបរទេសមានជាតិយួន ចិន កូរ៉េ សៀមជាដើមកាន់តែមានស្តុកស្តម្ភឡើងៗ។

មានសកម្មជន និងបងប្អូនជាច្រើនរូបបានឡើងថ្លែងចំណាប់អារម្មណ៍ និងដាក់សំណួរសុំការបំភ្លឺពីលោកស្រី មូរ សុខហួរ និងលោក ប៉ុល ហំម នូវ គោលការណ៍ និងបន្ទាត់នយោបាយរបស់គណបក្សសង្គ្រោះជាតិដែលមានរូបសញ្ញាព្រះអាទិត្យកំពុងរះឡើងបញ្ចេញកាំរស្មីចំនួន២៤គ្របដណ្តប់ទៅលើរាជធានី និងខេត្តទាំង២៤នៅកម្ពុជាយើងនេះ។

នៅក្នុងរាត្រីដ៏មានមហាកិត្តិយសនេះ បានប្រព្រឹត្តិទៅក្នុងបរិយាកាសប្រកបដោយមិត្តភាពភាតរភាព និងមេត្រីរាប់អានល្អប្រសើរយ៉ាងក្រៃលែងដែលចាត់ទុកថា ជាការបង្រួបបង្រួមគ្នាជួយគាំទ្រដោយអស់ពីកម្លាំងចិត្តកម្លាំងកាយកម្លាំងថវិកា ដើម្បីជួយចូលរួមចំណែកសង្គ្រោះជាតិមាតុភូមិរបស់ខ្មែរយើងទាំងអស់គ្នាឱ្យជាតិខ្មែរ បានរួចផុតពីមហាគ្រោះថ្នាក់។

ពិធីជប់លៀងទទួលស្វាគមន៍ លោកស្រី មូរ សុខហួរ និងលោក ប៉ុល ហំម បានបញ្ចប់នៅវេលាម៉ោង១០និង៣០នាទីយប់ប្រកបដោយបរិយាកាសសប្បាយរីករាយនិងស្និទ្ធស្នាលជាទីបំផុត។

រាយការណ៍ ដោយ: លោក ម៉ម យ៉ឹន ពីក្រុងហ្វីឡាដែលហ្វីយ៉ា៕

KHMER POST USA, LLC
East Coast Publication

**Pin Samkhon,**
*Publisher & Editor-in-Chief*
Email: pinsamkhon@gmail.com
*Staff Writers:* **Loeum Im**

*Contributed Writers:*
**Mam Yin, Kim Phien**
*Advertising Department*

**Soben Pin**
KhmerPostUSA@gmail.com
**267-253-3947**

**Sam Khoeun**
*Sales Consultant*
**(781) 244-0522**

*Design Staffs:*
**Leang Heng & Mong Meng**

KhmerPost USA, LLC is an independent newpaper that aims to facilitate mass communication among the Cambodian communities, their neighboring communities, and families. We aim to address local, community, and national news; and give an insight into Cambodia & global news. We also strive to bridge the language and cultural gaps and reduce social isolation by publishing in Khmer & English.
It published twice a month in Pennsylvanian & Massachusett.

Semimonthly edition subscription is available within the U.S. & Canada at $60.00 and 70 Euros in Europe per year.
Money order or check is accepted and made payable to:
KhmerPost USA, LLC
438 LINDLEY AVE.
Philadelphia, PA 19120

The Khmer Post has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009

Mekong River
VIETNAMESE RESTAURANT
1120-1124S Front St.,
Philadelphia, PA 19147
(Near Washington Ave. - មានកន្លែងចតឡានត្រឹមត្រូវ
215-467-6100



GRAND OPENING
25-5-2012

មានម្ហូបវៀតណាមគ្រប់មុខ B
ហ្វើ មី គុយទាវ នំបញ្ចុក បាញ់ហយ Y
បាយ ម្ហូបបួស ម្ហូបឆា ម្ហូប សម្រាប់ទទួលជាលក្ខណៈគ្រួសារ O
ទទួលពីធីជប់លៀងជាលក្ខណៈគ្រួសារ ឬជួបជុំមិត្តភ័ក្រ B




មានភោជនីយដ្ឋានទើបបើកនៅក្នុងសហគន៏យើង




តមកពីទំព័រទី ៧

## រដ្ឋាភិបាលក្រុងម៉ានិល និងក្រុងភ្នំពេញខ្វែង...

សេចក្តីថ្លែងការណ៍ រួមជាចុងក្រោយរបស់ខ្លួននេះ ជាលើកដំបូងនៃប្រវត្តិសាស្ត្រ៤៥ឆ្នាំរបស់ខ្លួន។

ជម្លោះព្រំដែនទឹកនៅជុំវិញ តំបន់ដែលសំបូរធនធានធម្មជាតិរវាងប្រទេស៤ជាសមាជិកអាស៊ានគឺប្រទេសហ្វីលីពីន វៀតណាម ម៉ាឡេ និងព្រុយនេ ជាមួយនឹងប្រទេសចិន។ ក្នុងពេលថ្មីៗនេះកាលពីខែមេសា នាវាកងទ័ពជើងទឹក និងឆ្មាំសមុទ្ររបស់ប្រទេសចិន បានប៉ះទង្គិចគ្នាជាមួយប្រទេសហ្វីលីពីន ពាក់ព័ន្ធក្នុងដែនសមុទ្រដែលមានជម្លោះនេះ។

ខណៈដែលមានប្រទេសជាសមាជិកអាស៊ានដែលបានអះអាងចង់ដោះស្រាយបញ្ហាជម្លោះតាមរយៈការចរចាជាពហុភាគីនិងសង្ឃឹមថាអាមេរិកបានចូលរួមក្នុងកិច្ចពិភាក្សានេះ ក្រុង ប៉េ ដែលមានជំហាតតងាករេបានអំពាវនាវឱ្យមានកិច្ចពិភាក្សាទ្វេរភាគីវិញ ដែលធ្វើឱ្យប្រទេសចិនមានឥទ្ធិពលថែមទៀតលើប្រទេសសមាជិកអាស៊ាន។

រដ្ឋមន្ត្រីក្រសួងការបរទេសឥណ្ឌូនេស៊ី លោក ម៉ាទី ណាតាឡេហ្គាវ៉ា(Marty Natalegawa)ដែលដើរជាអ្នកសម្របសម្រួលក្នុងបញ្ហាជម្លោះនេះ បានថ្លែងថា លោកបានសរសេរលិខិតមួយច្បាប់ជូនទៅមន្ត្រីហ្វីលីពីន អំពីការខ្វែងគំនិតគ្នានេះ ដោយលោកជឿថា ទស្សនទាំងនេះមិនស្របគ្នាទេ។

លោកណាតាឡេហ្គាវ៉ា ថ្លែងនៅក្នុងកិច្ចសម្ភាសខាងក្រៅកិច្ចប្រជុំកាលពីថ្ងៃអាទិត្យថា "កម្មវត្ថុពីរគឺមិនពិតជាដូចគ្នានោះទេ ហើយ ខ្ញុំបានសរសេរលិខិតផ្លូវការមួយផ្ញើជូនប្រទេសហ្វីលីពីន ជាសហការីរបស់យើង ដើម្បីអះអាងថាទស្សនរបស់ពួកគេគឺពិតជាមិនស្របតាមទស្សនដែលបានលើកឡើងនេះទេ ដែលបញ្ហានោះតាមពិតជំរុញឱ្យសហគមន៍អាស៊ានលើកឡើងបញ្ហានេះជាបញ្ហាមួយដែលគេយល់ថាសមរម្យ"។

លោកថ្លែងបន្តថា "ខ្ញុំមិនគិតថា យើងគួរព្រួយបារម្ភពេកទេអំពីពាក្យអន្តរជាតិ រឺមិនអន្តរជាតិនោះ។ នៅពេលចាប់ផ្តើមដំបូងបញ្ហានេះគឺជាបញ្ហាមួយដែលយកចិត្តទុកដាក់ទាំងថ្នាក់ទ្វេរភាគី រវាងប្រទេសដែលជាប់ពាក់ព័ន្ធទាំងអស់ និងនៅពេលដូចគ្នានេះដែរ នៅក្នុងបរិបទក្នុងតំបន់"។

ចាប់តាំងពីប្រទេសកម្ពុជាធ្វើជាប្រធានអាស៊ានមានភាពខ្វះខាតជាសាធារណនៅក្នុងប្លុកអាស៊ានអំពីបញ្ហានៃការដោះស្រាយជម្លោះសមុទ្រខាងត្បូង។

ក្នុងអំឡុងកិច្ចប្រជុំកំពូលអាស៊ាន កាលពីខែមេសា ប្រទេសកម្ពុជាបានជំរុញ ឱ្យប្រទេស ចិន

តទៅទំព័រទី១៦







SIM'S
Major Sim Enterprises, Inc.
Home Improvement
ជាងសំណង់គាស៊ីម
License#CS 88569 Registration#153685
978-452-7467 / 978-421-3672 / 978-420-8551
FREE ESTIMATES
60 Middlesex St. (Rte.110) Lowell. MA 01852
FULLY INSURED
ជួសជុល កែលំអរ សង់បន្ថែម
Kitchen ចង្ក្រានបាយ
Livingroom បន្ទប់ទទួលភ្ញៀវ
Bathroom បន្ទប់ទឹក
Bedroom បន្ទប់ដេក
Roofing ដំបូល
Siding ជញ្ជាំង
Window បង្អួច
Door ទ្វារ
Basement ជាន់នៅក្រោមដី
Additions បន្ទប់បន្ថែម
Residential • Commercial • Industrial
ទទួលប្រាក់គ្រប់ប្រភេទ
Bank Loan, Insurance, Compensation, Credit Debit Card, Check &Cash
More information call: 1.978.452.7467
www.simshomeimprovement.com
Boreth@simshomeimprovement.com


Phở BOSTON
Authentic Vietnamese Cuisine
Vietnamese & Chinese Restaurant
ភោជនីយដ្ឋាន
ហ្វើ បូស្តុន
ម្ហូបវៀតណាមពិតប្រាកដ
ភោជនីយដ្ឋានវៀតណាម និង ចិន
បើកទ្វាររាល់ថ្ងៃ
ពីម៉ោង១០ព្រឹក
ដល់១០យប់
Phở BOSTON
144 Shield St. West Hartford CT
Phone.(860) 953-8678
Website.www.phoboston.com


ភោជនីយដ្ឋាន
កុលាបក្រហម
Red Rose
RESTAURANT
ម្ចាស់ថ្មី _ម្ហូបឆ្ងាញ់
Mon-Sun
8am -7:30pm
សម្លម្ជូរ គ្រឿង $11.99
*ម្ហូបឆ្ងាញ់ជាងមុន តែតម្លៃនៅថោក ដូចមុនដដែល
*សេវាកម្មរហ័សទាន់ចិត្ត និងរួសរាយរាក់ទាក់
(978) 452-5400
Pailin Plaza
716 Middlesex St. Ste 1
Lowell, MA 01851


ហាងមាស គីម ង៉ុក
នៅវេសហាតហ្វឺត
KIM NGOC
JEWELRY
មានលក់ដុំ ឬរាយ ឬដូរ ឬធ្វើប័ណ្ណសំរាប់
អំណោយមានធ្វើប្លែនពន្យាពេលបង់ប្រាក់
-ទទួលសាំទ់បញ្ចាំ មានចុះថ្លៃរហូតដល់ ៦៥%
សម្រាប់ ពេជ្រមកពីហុងកុង មានជាងអលង្កា
នៅក្នុងហាងជួសជុលបានភ្លាមៗ
ពេលវេលាបើក : ថ្ងៃច័ន្ទ ដល់ថ្ងៃអាទិត្យ
ពីម៉ោង ១០ព្រឹកដល់៧ល្ងាច
Open: Mon-Sun:
10am-7pm
150 Shield Street Plaza. West Hartdord, CT 06110
Tell: (860) 953-5803, Fax:(860)953-5802

KhmerPost USA
Printing The Cambodian World News


Pin Samkhon

## Print Edition Now is Available on the World Wide Web at:

## www.khmerpost.us

# Impact of the KhmerPost USA

The KhmerPost USA is the only Cambodian newspaper that has the highest circulation and is most read in the Cambodian communities in the East Coast of United States. The newspaper prints between 24 to 32 pages an issue. It provides important news and information to a market that is often isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. Found in 2007 by a respectable Cambodian Journalist, Roger Samkhon Pin, the former President of Cambodian Journalist Association of Cambodia (1994-1997), the Director of Radio Free Asia, Cambodian Services in Washington D.C (1998-2003), and the founder and broadcaster of Cambodian-American news through five Radio Stations around the U.S (2004-2008).

## Publication Frequency

**24 times a year. Prints on every other Friday**
(Skips three Fridays on May 31st, August 30th & November 29th, 2013)

## General Information

**Circulations**: 20,000 copies per month.
**Distributions:** 100+ locations in Lowell, MA (25,000+ Cambodians, 20% of Lowell's total population)
50+ locations in Lynn, Revere, Springfield, Worcester, MA
50+ locations in Hartford, West Hartford & Danbury, CT and Providence & Cranston, RI
100+ locations in Philadelphia, PA, and Camden & Pennsauken, NJ
**Readership**: 50,000+ and is growing to New York and Connecticut in Winter 2012.
**Subscriptions**: USA, Canada, and France.
**Publication Stock**: #35 Newsprint, Binding: Tabloid, Printing Process: Web press

## PhmerPost USA 2013 Publication Dates

| | | | |
|---|---|---|---|
| January 11th, 2013 | January 25th, 2013 | July 5th, 2013 | July 19th, 2013 |
| February 8th, 2013 | February 22nd, 2013 | August 2nd, 2013 | August 16th, 2013 |
| March 8th, 2013 | March 22nd, 2013 | September 6th, 2013 | September 20th, 2013 |
| April 5th, 2013 | April 19th, 2013 | October 4th, 2013 | October 18th, 2013 |
| May 3rd, 2013 | May 17th, 2013 | November 1st, 2013 | November 15th, 2013 |
| June 7th, 2013 | June 21st, 2013 | December 6th, 2013 | December 20th, 2013 |

## Advertising Information

Massachusetts (978)-656-8141/(781) 244-0522
Connecticut/Rhode Island: (860) 461-3686
Pennsylvania/New Jersey/New York: (267) 253-3947
info@khmerpost.us/KhmerPostUSA@gmail.com
www.khmerpost.us

Massachusetts Home Office. 32 Wamesit St. Suite 1. Lowell, MA 01852. Pennsylvania: 5730 Rising Sun Avenue. Philadelphia, PA 19120
Direct Voice: (978) 656-8141/(267) 253-3947/Email: KhmerPostUSA@gmail.com. www.khmerpost.us

## តមកពីទំព័រទី ៣ ដល់ពេលអ្នកមាន និងអ្នកក្រត្រូវជួយគ្នាទៅវិញ...

សេដ្ឋកិច្ចត្រូវយ៉ាងតិច១០ភាគរយ ទើបអាចបន្ថយភាពក្រីក្រលឿនសមរម្យបាន។ ឧទាហរណ៍ប្រទេសចិនក្រហមក្នុងចំនួន១០ឆ្នាំមុននេះ សេដ្ឋកិច្ចឡើងជាមធ្យមជាង១០ភាគរយក្នុង១ឆ្នាំៗ ទើបតែឆ្នាំ២០១២នេះចុះនៅត្រឹមជាង៧ភាគរយ។ ដូច្នោះការកើនឡើងនៃសេដ្ឋកិច្ចនៅប្រទេសខ្មែររវាង៧និង៨ភាគរយនោះមិនបានកាត់បន្ថយភាពក្រីក្រប៉ុន្មានទេ ។ សូមបញ្ជាក់អំពីទឹកប្រាក់នៃផលិតផលក្នុងស្រុករួមរបស់មនុស្សម្នាក់ៗឬ GDP per capita ។ ដើម្បីរកឃើញនូវ GDP per capita យកGDPមក ចែកនឹងចំនួនប្រជាពលរដ្ឋទាំងអស់។ នៅឆ្នាំ២០១១ GDP ខ្មែរមានជាទឹកប្រាក់ប្រមាណ១៣ពាន់លានដុល្លាសហរដ្ឋអាមេរិក ហើយចំនួនប្រជាពលរដ្ឋខ្មែរមានប្រមាណ១៤លាននាក់។ ដូច្នេះយក១៣ពាន់លានមកចែកនឹង១៤លាននឹងឃើញ៩២៨.៥៧នេះជា GDP per capita ។ ប៉ុន្តែតាមការស្រាវជ្រាវដែលមានលេខត្រឹមត្រូវGDP per capitaត្រឹមត្រូវតែ៩១២ទេ។

ហើយចំពោះរឿងធនធាននេះទៀត មិនទាន់មានការស្រាវជ្រាវណាមួយបង្ហាញតួលេខថាអ្នកមានមានធនធានប៉ុន្មាន ហើយអ្នកក្រមានធនធានប៉ុន្មានទេ។

ប៉ុន្តែបើយើងសង្កេតមើលទៅយើងឃើញថាខ្មែរមួយភាគតូចរស់នៅក្នុងផ្ទះថ្មមានម៉ាស៊ីនត្រជាក់ ធ្វើការក្នុងបន្ទប់មានម៉ាស៊ីនត្រជាក់ បើកឡានថ្មីៗ ហើយទំនើបៗ ចូលហាងបាយថ្លៃៗបញ្ជូនកូនទៅរៀននៅសាលាឯកជនថ្លៃៗនៅក្នុងស្រុកឬនៅបរទេស ហើយយើងថែមទាំងឮថាអ្នកខ្លះមានលុយដល់ទៅរាប់រយលានដុល្លាសហរដ្ឋអាមេរិកដាក់នៅធនាគារនៅបរទេសទៀតផង។

ហើយយើងក៏ឃើញដែរថាខ្មែរមួយភាគធំ



លោក គិត ម៉េង អ្នកមានស្រុកខ្មែរជិះឡានរ៉ូលរ៉យ

ឬក៏អាចថាបានភាគច្រើនកំពុងត្រដររករស់។ ខ្លះគ្មានទាំងដីទាំងផ្ទះនៅ ។ ខ្លះនៅផ្ទះដែលមិនគ្រាន់តែប្រៀបបាននឹងសំបុកសត្វទេថែមទាំងសង់នៅកន្លែងភក់ជ្រាំធុំក្លិនស្អុយ។ និយាយឱ្យខ្លីខ្មែរជាង៦០ភាគរយនៃប្រជាពលរដ្ឋទាំងអស់គ្មានទឹកស្អាតហូបគ្មានបង្គន់អនាម័យប្រើប្រាស់ និងនៅនឹងកន្លែងដែលអាចបណ្តាលឱ្យមានការប៉ះពាល់ដល់សុខភាពឱ្យមានការខ្វះសន្តិសុខនិងឱ្យមានគ្រោះថ្នាក់ដល់ជីវិតគឺកន្លែងដែលធ្លាក់ចូលក្នុងស្ថានការណ៍ដែលញ៉ាំងឱ្យគិតទៅឃើញតែរឿងលំបាកវេទនាឬសេចក្តីស្លាប់ច្រើនជាងរឿងរស់នៅក្នុងភាពធម្មតា ។ ដូច្នេះតើសេចក្តីសង្ឃឹមដើម្បីនឹងរស់នៅឯណាទៅ ?

ចំពោះកន្លែងធ្វើការនៃក្រុមខ្មែរភាគច្រើននេះវិញ យើងសង្កេតមើលទៅឃើញថា កន្លែងខ្លះមិនបង្ហាញឱ្យឃើញថាមានការគិតដល់សុខភាពនិងគ្រោះថ្នាក់ដល់មនុស្សទេ។ ឧទាហរណ៍នៅរោងចក្រដេរខោអាវកម្មកររាប់សិបទៅដល់រយនាក់ដួលសន្លប់ស្ទើរតែរាល់ខែ។

ដើម្បីនឹងរស់ក្នុងចំណោមភាគច្រើននេះ ខ្លះធ្វើអ្វីៗស្ទើរតែទាំងអស់ទាំងពីរើសម្ហូបពីសម្រាមមកហូបលក់ខ្លួនយកកូនទៅលក់រកមធ្យោបាយគ្រប់បែបយ៉ាងដើម្បីចេញពីស្រុកខ្មែរទាំងពីប្រថុយស្លាប់ជាដើម ដើម្បីរកការធ្វើសម្រាប់តែរស់តែប៉ុណ្ណោះ។ ចំពោះអ្នកចេញពីស្រុកនោះមកដល់ពេលនេះតាមព័ត៌មានខ្មែរជាង៥សែននាក់ទាំងតាមផ្លូវច្បាប់ និងក្រៅផ្លូវច្បាប់ធ្វើជាកម្មករនៅប្រទេសក្រៅ គឺនៅប្រទេសថៃ ប្រទេសម៉ាឡេស៊ី ប្រទេសកូរេខាងត្បូង និងកោះតៃវ៉ាន់ជាដើម។ សូមបញ្ជាក់ថា ក្រុមកម្មករនេះតស៊ូក្នុងដំណើរស្លាប់រស់ដើម្បីរកលុយបន្តិចបន្តួចយកមកចិញ្ចឹមជីវិតសម្រាប់តែរស់ប៉ុណ្ណោះ។

សព្វថ្ងៃនេះ ដើម្បីនឹងរស់បានការត្រូវការលុយកាន់តែច្រើនឡើងៗ ដូចជានៅភ្នំពេញតាមការសង្កេតនិងប៉ាន់ស្មានមនុស្សម្នាក់ដើម្បីនឹងរស់ឱ្យបានសមរម្យបានត្រូវការ៣៥០ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ។ នេះបង្ហាញឱ្យឃើញថា មនុស្សភាគច្រើនមិនថានៅភ្នំពេញឬខេត្តក្រៅណាទេរស់មិនបានសមរម្យទេ។ ដើម្បីបញ្ជាក់ឱ្យឃើញថា ភាគច្រើនរស់មិនបាបានសមរម្យយើងសង្កេតមើលប្រាក់ចំណូលរបស់កម្មករនិងគ្រូបង្រៀន ។ ប្រាក់ខែកម្មករតែប្រហែល៨០ដុល្លារសហរដ្ឋអាមេរិកយ៉ាងច្រើនក្នុង១ខែ ហើយប្រាក់ខែគ្រូបង្រៀនប្រហែលតែ១០០ដុល្លាសហរដ្ឋអាមេរិកក្នុងមួយខែតែប៉ុណ្ណោះ។

ដូច្នេះ ទោះជាស្ថិតិចង្អុលថាចំនួនអ្នកក្រចុះពី៣៧ភាគរយនៅឆ្នាំ១៩៩៧មកដល់៣១ភាគរយនៅឆ្នាំ២០០៧ក៏ដោយ តាមការសង្កេតរបស់យើងរួមផ្សំនឹងរបាយការណ៍របស់ក្រុមអ្នកប្រាជ្ញអាល្លឺម៉ង់ យើងឃើញថាចំនួនអ្នកក្រកាន់តែកើនឡើងៗនិងធនធានកាន់តែថយទៅៗហើយឆ្ងាយទៅឆ្ងាយទៅបើប្រៀបធៀបធនធានរបស់អ្នកមាន ព្រោះថា ធនធានរបស់អ្នកមានឡើងច្រើនឡើងៗ ហើយលឿនឡើងៗដែរ។

មួយទៀតយើងឃើញថា ភាពក្រីកំពុងធ្វើឱ្យមនុស្សលះបង់សេចក្តីថ្លៃថ្នូរនិងជីវិតទៀតផង។

និយាយមកនេះសឱ្យឃើញថាស្រុកខ្មែរចាប់ធ្វើដំណើរសន្សឹមៗទៅទិសបញ្ហា ។ខ្ញុំជឿថាអ្នកមាននិងអ្នកក្រអាចជួយរដ្ឋាភបាលដោះស្រាយបញ្ហានេះបាន។

**កំណត់:** ខ្ញុំសូមស្នេះត្រឹមនេះសិន។ នៅលើកក្រោយខ្ញុំនឹងលើកមកវែកញែកជូននូវ

១.តើអ្នកមាននិងអ្នកក្រគួរដោះស្រាយបញ្ហានេះយ៉ាងរបៀបណា?

២.ហេតុអ្វីបានជាភាពមាននិងភាពក្រធ្វើឱ្យមនុស្សបែកបាក់គ្នា? និង

៣. គួរធ្វើយ៉ាងដូចម្តេចឱ្យអ្នកមាននិងអ្នកក្រត្រូវគ្នាបាន។

សូមទាក់ទងនឹងខ្ញុំតាម
e-mail soskem@yahoo.com (kwmsus) ។



នាទី ប្រវត្តិសាស្ត្រ

## ពីរដ្ឋបាលកុលសម្ព័ន្ធមករដ្ឋាភិបាលសម័យ

(នៅមានត)

**១៦ ឧសភា :** រដ្ឋាភិបាលខ្មែរសុំជំនួយយោធាទៅអូស្ត្រាលី-អាមេរិក នឹងបារាំង-ប្រទេសថៃប្រកាសជំទាស់គ្រប់រូបភាពជំនួយដល់យោធារដ្ឋាភិបាលខ្មែរ រិបអូសកាសែត ១០.០០០ច្បាប់នៅការិយាល័យកាសែត "សាកល" ពីបទមើលងាយព្រះមហាក្សត្រ ។

**១៧ ឧសភា :** សីហនុ កោះប្រជុំគ្រប់គណបក្សដោយគ្មានដាក់លក្ខខណ្ឌជាមុននៅព្យុងយ៉ាងសម្រាប់ថ្ងៃ១៧ឧសភា ។

**១៨ ឧសភា** សីហនុ ចេញដំណើរទៅប៉េកាំង

២១ ឧសភា មានការចាប់ពង្រត់ជនវៀតណាម ៤រូប ។

**២៧-២៨ ឧសភា :** ប្រជុំគ្នានៅព្យុងយ៉ាង (កូរ៉េខាងជើង) ដោយមានគ្រប់គណបក្សក្នុងស្ថាប័នរួមទាំងខ្មែរក្រហម ក្រោមអធិបតីភាពព្រះមហាក្សត្រ-លទ្ធផលបរាជ័យ ។

**៧ មិថុនា ១៩៩៤ :** រដ្ឋាភិបាលហាមឃាត់ការផ្សាយរបស់កាសែត "ព្រហ្មបាយ័ន"

**១១មិថុនា ១៩៩៤ :** នាយកកាសែតអន្តរាគមន៍ឈ្មោះ ធូនោម មង្គល បានត្រូវគេធ្វើទារុណកម្មរហូតដល់ស្លាប់លោកជាអតីតអ្នកទទួលខុសត្រូវផ្នែកស៊ើបអង្កេតរបស់រដ្ឋកម្ពុជា ។ អង្គការលើកលែងទោសពិភពលោកសង្ស័យថាឃាតកម្មនេះបណ្តាលមកពីការទិទៀនសកម្មភាពរដ្ឋាភិបាល ។

**១៥-១៦មិថុនា :** ប្រជុំមូលជាថ្មីម្តងទៀតក្នុងលក្ខណៈបច្ចេកទេសតែត្រូវបរាជ័យដដែល

**១៧ មិថុនា :** រដ្ឋាភិបាលសរសេរលិខិតឱ្យតំណាងខ្មែរក្រហមចាកចេញពីភ្នំពេញមុនថ្ងៃ ១៩

**១៩មិថុនា :** ការិយាល័យតំណាងខ្មែរក្រហមបានត្រូវបិទទ្វារ -បុគ្គលិកក៏ត្រូវចាកចេញពីភ្នំពេញរដ្ឋមន្ត្រីការបរទេសថៃ សម្តែងការមិនពេញចិត្តចំពោះការបិទទ្វារនេះ

**២៣មិថុនា :** សម្តេច សីហនុ បានធ្វើបទសម្ភាសន៍យ៉ាងវែងឱ្យ Fare Eartern Economic Review នៅហុងកុងនិយាយទិទៀនចំពោះរាជរដ្ឋាភិបាល ។

**២៨មិថុនា :** គណបក្សប្រជាជនប្រារព្ធពិធីខួបកំណើត "សាធារណរដ្ឋប្រជាមានិតកម្ពុជា" ហើយបញ្ជាក់ពីការបន្តនយោបាយ ដែលបញ្ចូលឱ្យប្រើរហូតមកដល់ឆ្នាំ ១៩៩១ នៃរបបកុម្មុយនីស្ត **តទៅលេខក្រោយ**

នាទី ព្រះពុទ្ធសាសនា

## ពុទ្ធប្បវត្តិអមដោយរូបភាព

**៨-កន្លែងចង្រ្កមភាវនា (ពុទ្ធគយា)**

នៅភាគខាងជើងនៃពុទ្ធគយាមាននៅសល់ចម្លាក់ផ្កាឈូកមួយជួរដែលឆ្លាប់នឹងថ្ម ដើម្បីរំលឹកដល់ទីកន្លែងដែលព្រះពុទ្ធជាម្ចាស់ទ្រង់និមន្តចង្រ្កមភាវនា ។ នៅព័ទ្ធជុំវិញទីចង្រ្កមនេះ មានចេតិយ៍តូចៗជាច្រើនដែលកសាងឡើងដោយពួកបរិស័ទ ។

**៩-ព្រះពុទ្ធរូបធ្វើទុក្ករកិរិយា (ថ្មភក់, គន្ធារ,សតវត្សទី២៣)**

កាលដែលព្រះពុទ្ធទ្រង់ពុំទាន់បាន សម្រេចការត្រាស់ដឹងនៅឡើយ ព្រះអង្គទ្រង់បានធ្វើទុក្ករកិរិយាជាច្រើនបែប ដោយយកព្រះទ័យទុកដាក់, យ៉ាងប្រុងប្រយ័ត្ន និងខ្លាំងក្លាបំផុតនៅក្បែរភូមិឧរុវេលាស្រុកគយា ត្រង់ស្ទឹងនេរញ្ជរា ។ ព្រះអង្គទ្រង់កាត់បន្ថយការឆាន់ចង្ហាន់បន្តិចម្តងៗរហូតដល់ព្រះកាយប្រែជាខ្សោយទៅ, ស្គមទៅមើលឃើញតែសរសៃ និងឆ្អឹង ។ ប៉ុន្តែព្រះអង្គនៅតែមិនអាចបានសម្រេចការត្រាស់ដឹងក្នុងការធ្វើទុក្ករកិរិយាដ៏លំបាកតាមរបៀបដូចនេះ, ព្រោះហេតុដូច្នោះហើយ ព្រះអង្គក៏ឆាន់ចង្ហាន់ឡើងវិញដើម្បីញាំព្រះកាយឱ្យមានកម្លាំងដូចធម្មតា ។

**តទៅលេខក្រោយ**

**8-The site of the Cangramana(Buddhagaya)**



On the northern site of Buddhagaya there are the remains of a row of lotus flowers cared in stone that is to commemorate the place where the Buddha went pacing hither and tither. Surrounding it there are many little stupas offered by devotees.

**9- The image of the Buddha Practicing Austerities (Sandstone, Gandhara, 2nd-3rd century)**



When the Buddha had not yet attained full illumination he praticed diligently, heed fully and stric tly austerities in the vicinity of the Uravilva village in Gaya at the Nairanjara River. He gradually reduced his food until the body became weak and emaciated with the sinews and bones showing up. But he could not attain full illumination practicing austerity in this way he therefore began to take food to uphold his bodily strength.

## សូមជាតិខ្មែរ ត្រូវជួយមូលនិធិសង្គ្រោះជាតិ

១-ឱះឱជាតិខ្មែរសែនថ្លៃថ្លា
ជាជាតិខ្មែរពិតចិត្តជ្រះថ្លា
រស់ក្នុងលោកា នឹងកម្ពុជា
ជួយជាតិគ្រប់គ្នាសែនប្រពៃ ។
២-ពេលនេះជាពេលសំខាន់ណាស់
ត្រូវតែភ្ញាក់ឡើងតាំងស្មារតី
ជាតិខ្មែរយល់ច្បាស់គ្មានសង្ស័យ
សង្គ្រោះជាតិខ្មីពីសត្រូវ ។
៣-មាតុភូមិជាតិខ្មែរត្រូវរងទុក្ខ
ដោយសារមានមេដើរខុសផ្លូវ
មានខ្មាំងលុយលុកខ្លាំងពេកកូវ
ចិត្តសែនឈោរឃៅក្បត់ជាតិឯង ។
៤-មេនេះសែនជោរពោរពេញខ្មាត
គិតតែរួមចិត្តឥតកោតក្រែង
ចិត្តសែនគ្រោតគ្រាតយ៉ាងជាក់ស្តែង
ហើយស្រែកក្តែងៗថាស្នេហ៍ជាតិ ។
៥-ពេលនេះជាពេលមកដល់ហើយ
រួមសាមគ្គីគ្នាដោយចិត្តស្អាត
ឱជាតិខ្មែរអើយត្រូវខ្មីឃ្មាត
ចូលរួមព្រោងព្រាតផ្តល់ថវិកា ។
៦-ទោះតិចឬច្រើនដោយចិត្តស្មោះ
អ្នកមានតែ១ឬពាន់ដុល្លារ
មានន័យសង្គ្រោះតាមសទ្ធា
អាចចូលរួមគ្នាមូលនិធិ ។
៧-ដើម្បីសង្គ្រោះជាតិខ្មែរពិត
ស្មារតីស្នេហ៍ជាតិមានសិទ្ធិ
ឱ្យរស់ជីវិតមានសតិ
ឧត្តមគតិខ្មែរជាតិនិយម ។
៨-សូមជាតិខ្មែរអើយងើបឈរឡើង
មិនត្រូវនៅស្ងៀមដេកសំងំ
សង្គ្រោះជាតិយើងខ្មែរឧត្តម
មិនព្ទខ្មែរយំទេឬអី? ។
៩-បើខ្មែរពិតជាជាតិខ្មែរមែន
ចូលរួមមូលនិធិសង្គ្រោះខ្មែរថ្មី
សូមខ្មែរត្រូវកេណ្ឌទាំងប្រុសស្រី
ជាតិល្អប្រពៃសែនឧត្តម ។
១០-មូលនិធិសង្គ្រោះជាតិខ្មែរពិត
ឱ្យមាតុភូមិខ្មែររួចទុក្ខធំ
ស្រោចស្រង់ជីវិតពិតរឹងមាំ
សុខសាន្តមនោរម្យរុងរឿងហើយ ។
១១-សូមលើកមាតាទាំង២ផ្តុំ
ជាពរល្អណាស់ពិតថ្លៃល្អើយ
ជូនពរឧត្តមព្រះផ្តល់ឱ្យ
បានសុខជាស្បើយកើនចម្រើន ។
១២-មានជោគមានជ័យស្រីបវរ
រុងរឿងថ្លៃថ្លាជួយបង្កើន
កើតមានពេញពោរកើនយ៉ាងច្រើន
ច្រើនឡើងរន្ថើនបរិបូរហោង ។

សូមអរគុណ

**កំណាព្យ និពន្ធដោយ លោក ម៉ម យឺន**

Neighborhood Health Plan of Rhode Island
តើលោកអ្នកត្រូវការធានារ៉ាប់រងផ្នែកសុខភាពឬ?
សូមទូរស័ព្ទទាក់ទងក្រសួងណេបើរហ៊ូដថ្ងៃនេះ
Need Health Insurance?
Call Neighborhood Today
1-401-459-6171
www.nhpri.org



# ប្រវត្តិរណសិល្បជាតិរំដោះប្រជាពលរដ្ឋខ្មែរ

# រ.ជ.រ.ប.ខ លោកតា សឺន សាន




ដោយ : ម៉ម យ៉ឹន

(តពីលេខមុន)



ដូច្នោះរថយន្ត តូយូតា រត់កង់បួន (TOYOTA 4WD) ពីរគ្រឿងមួយគ្រឿង បើកបរដោយខ្ញុំបាទផ្ទាល់ និង១គ្រឿងទៀត បើកបរដោយទាហានថៃជាអ្នកនាំផ្លូវបានបើកសំដៅទៅកាន់ភ្នំម៉ាឡៃដោយឆ្លងកាត់តាមផ្លូវដីមានទឹកលេចយ៉ាងជ្រៅពុំអាចមើលថ្នល់ឃើញទេ ហើយបើកបរពេលយប់ងងឹតមានភ្លៀងរលឹមស្រិចៗផង ។ ដូច្នេះការបើកបរបានជួបប្រទះការលំបាកខ្លាំងណាស់ ប៉ុន្តែទោះបីជាយ៉ាងណាការពុះពាររបស់ខ្ញុំបាទ និងទាហានថៃត្រូវតែបានសម្រេចទៅដល់ទីដៅដោយសុវត្ថិភាព រួចហើយរង់ចាំទទួលយកក្រុមអ្នកសារព័ត៌មានទាំងនោះ ។

គួរឱ្យអានោចអាធមណាស់ពេលខ្ញុំបាទបញ្ឆាំងភ្លើងឡានបំភ្លឺទៅស្រាប់តែឃើញអ្នកសារព័ត៌មានទាំង៤នាក់ មានស្បែកពាក់តែខោខ្លី និងអាវដៃខ្លីទទូសំពត់កៅស៊ូ ឱបម៉ាស៊ីនកាមេរ៉ាថតរូប រុំដោយថ្លាស្ទិច ទទឹកជោក ហើយរងាកខាក់ដោយពេលនោះមានភ្លៀងស្រិចៗផង ហើយធ្វើដំណើរកាត់ទឹកតាមវាលស្រែផង ។ រីឯដំណើរក៏សឹងតែឈានជើងដើរពុំរួចទេ ពីព្រោះតែមានរបួសជើងដោយសារតែការដើរកាត់ទឹកមកជាយូរថ្ងៃ ។ ឃើញសភាពការណ៍ដូច្នេះ ខ្ញុំបាទបើកទ្វារឡានរត់ចេញទៅជួយគ្រាហ៍អ្នកកាសែត១រូបដែលឃើញធ្ងន់ធ្ងរជាងគេ នាំមកកាន់រថយន្តជាបន្ទាន់ ។

ពេលនោះនៅក្នុងរថយន្តបានត្រៀមភួយ និង

តទៅលេខក្រោយ

ក្រុមហ៊ុនទេសចរណ៍អន្តរជាតិ អង្គរ

ក្រុមហ៊ុនទេសចរណ៍អន្តរជាតិ-អង្គរ

(Since 1991)

Angkor International Travel Agency




ទទួលផ្ញើរប្រាក់ទៅស្រុកខ្មែរ សេវាអន្តោប្រវេសន៍
សេវាលិខិតឆ្លងដែន កក់សណ្ឋាគារ ឬជួលឡាន

**USA**
4931 N. Old York Rd.
Philadelphia, Pa 19141
Tel: (215) 329-2036
Fax: (215) 329-7176
General Manager NARY PO
angkortravelphilly@yahoo.com

**Cambodia Office: Victory Travel (Skin Belle)**
No 57B, Eo Street 205 Touls Svay Prey 2.
Phnom Penh, Cambodia.
Ms. Chenda: 023-221069 * 012-851575
Or Mr. Sin Po: 012 429407 * 011-541111.

SERVING SINGAPOR, EVA AIR,CHINA, ASIANA KOREAN AILINES

ក្រុមហ៊ុនធានារ៉ាប់រងដែលបាន
បំរើសង្គម២២ឆ្នាំហើយ

CONWAY INSURANCE



For over 23 years, **Conway Insurance Agency** has been your community's one-stop provider of quality insurance services in New England.
We are a **full-service agency** offering:

- Personal Insurance
  - Autos
  - Homes
  - Apartments
  - Jewelry
  - Fine arts
  - Collectibles
- Business Insurance
  - Property
  - Liability
  - Professional Liability
  - Worker's compensation
  - Bonds
  - Auto, Garage keepers.
  - Disability and life insurance (individual and group products)
  - Other specialty programs

ក្រុមហ៊ុនធានារ៉ាប់រង ផ្ទះ រថយន្ត
មុខរបរ និងសុខភាព

**យើងនិយាយភាសាខ្មែរ**

CONWAY
INSURANCE AGENCY

P.O. Box 1744
77 E. Merrimack Street
Lowell, MA 01853
Tel: 978-454-5054
Fax: 978-453-2480

www.ConwayInsurance.com

សូមសួររក Philip Muth, Philip@ConwayInsurance.com

East Coast Center

for Plastic & Laser Surgery

Mai Ngoc Tran, M.S., Skin Care Specialist
Joseph A. Russo, M.D. F.A.C.S
Plastic & Reconstructive Surgeon
www.eastcoastsurgery.com



Skin Care Products | Tummy Tuck | Breast Lift | Beast Enlargement



Nose Surgery | Eyelid Surgery | Face Lift | Dermabrasion

ហាងកែសម្ផស្សយើងខ្ញុំមានទទួលកែសម្ផស្ស បុរស_ស្ត្រី ដែលមាន
អាការៈដូចជា: ខ្លាញ់ក្បាលពោះ ពង្រីកសុដន់ឱ្យធំ កែខ្ទង់ច្រមុះ
កែត្របកភ្នែក កែមុខស្រស់ស្អាត...។ល។ និង។ល។
និងមានលក់ឧបករណ៍កែសម្ផស្សផ្សេងៗជាច្រើនទៀត

381 West Broadway South Boston, MA 02127
(617) 464 - 0001

តមកពីទំព័រទី ១០ រដ្ឋាភិបាលក្រុងម៉ានិល និងក្រុងភ្នំពេញខ្វែង...

ចូលរួមក្នុងកិច្ចពិភាក្សា លើបញ្ហាសំខាន់មួយចំនួនក្នុងតំបន់អាស៊ាន និងសេចក្តីព្រៀងច្បាប់នៃការអនុវត្តន៍ក្នុងសមុទ្រចិនខាងត្បូង។ ទោះជាយ៉ាងណា ប្រទេសហ្វីលីពីនបានជំទាស់មិនឱ្យប្រទេសចិនចូលរួមក្នុងកិច្ចពិភាក្សានោះទេ ដោយអះអាងថា ចំណុចសំខាន់ៗក្នុងក្រមប្រតិបត្តិ គួរត្រូវបានសម្រេចដោយរដ្ឋជាសមាជិកអាស៊ាន មុនដាក់បញ្ចូលប្រទេសចិន។

អ្នកវិភាគបានលើកឡើងពីកិច្ចប្រជុំកំពូលអាស៊ានក្នុងសប្តាហ៍នេះថា គឺគ្រាន់តែជាកិច្ចប្រជុំមួយតាមទម្លាប់តែប៉ុណ្ណោះ គឺធ្វើឡើងតាមបំណងរបស់ចិនតែប៉ុណ្ណោះ។

កាលពីថ្ងៃអាទិត្យនាយករដ្ឋមន្ត្រីចិន វេន ជាប៉ាវបានសន្យាផ្តល់ជំនួយឥតសំណងចំនួន៥០លានដុល្លារឱ្យកម្ពុជា ក្នុងអំឡុងកិច្ចប្រជុំជាមួយនាយករដ្ឋមន្ត្រីហ៊ុន សែន។ លោកខាលី ថាយ៉ា (Carlyle Thayer) សាស្ត្រាចារ្យនៅសាកលវិទ្យាល័យ New South Wales នៅសាលាបណ្ឌិតសភាយោធានៃក្រសួងការពារជាតិអូស្ត្រាលី ដែលជាអ្នកជំនាញខាងបញ្ហាតំបន់អាស៊ានមួយរូប បានមានប្រសាសន៍ថា "នេះទំនាក់ទំនងជាឧទាហរណ៍មួយទៀត ដែលថា ប្រទេសកម្ពុជាកំពុងព្យាយាមបញ្ចុះបញ្ចូលប្រទេសជាសមាជិកអាស៊ានមិនឱ្យមានជម្លោះជាមួយប្រទេសចិនតាមគោលការណ៍ដ៏ស្មោះត្រង់របស់ខ្លួន។ សកម្មភាពរបស់កម្ពុជាគឺគ្រាន់តែបម្រើប្រទេសជាសមាជិកអាស៊ានក្នុងនាមជាប្រធានតែប៉ុណ្ណោះ"៕




Agent: Roeut Chak

# PK Property, Inc.

ក្រុមហ៊ុនអចលនវត្ថុ លក់ ជួល គ្រប់ប្រភេទ

ភីខេ ប្រភឺធី (215) 635-5100
Roeut Chak - (267)872-3516
409 West Cheltenham Avenue
Melrose Park, PA 19027

**សម្រាប់បើកភោជនីយដ្ឋានខ្មែរ**
- 5706 N. 5th Street, Philadelphia PA 19120

ពីដើមជាភោជនីយដ្ឋាន ឥឡូវបិទ២000sqft បន្ទប់ដេកបី ជាន់ទី២ជា Apt គ្រឿងបរិក្ខាទាំងអស់នៅក្នុងផ្ទះឈ្នួល២000/ខែ

5734 N.2nd Street, Philadelphia, PA 19120
២៥00 sqft ពីដើមជាភោជនីយដ្ឋាន មានកន្លែងចតឡាន៧៥- ឈ្នួល ២១00/ខែ

**កន្លែងភ្លក់បៀរ BEER DELI**
- $16000/wk, Phila, Asking $99,000w/ Real Estate
- $13000wk, Phila., Asking $79,000w/ Real Estate
- $9000/wk, Asking $320.000
- $13,500/wk Asking $42000

**កន្លែងបោកគក់ដាក់កាត Co. Laundry**
- 100 Machines, 4500 sqft Asking $170,000
- $4500/wk Asking $200000
- 500/wk Bucks County; Asking $350,000

**កន្លែងចែកចាយបៀរ** Beer Distributor
- $1.3 Mil/yr, Bucks County, $250000 yearly income, Asking $1,150,000
- $75000/yr Philadelphia Asking $790,000 with RE
- 11,000,000 Philadelphia Asking $430,000

**សាឡងធ្វើក្រចក Nail Salon**
- $18000/wk, Montgomery County, Asking $380,000
- $15000/wk South Jersey Asking $370,000

**សូមចូលទៅវេបសាយ**
www.pkpropertyinc.com to check more listings and office information.



## Foodtruck Business for Sale

Income: 5,000 dollars a week. Open only 5 days!
Location: 17th street and Spring Garden -Philadelphia
Contact: **215 586 1030**





# ផ្សារអាតាឡង់ទីក

Atlantic Market

135 main St, Danbury, CT 06810

**203-830-3068**




ផ្សារនេះមានម្ចាស់ឈ្មោះ **ដាន់ ស៊ីខ** បើកលក់ដូរតាំងពី១០ឆ្នាំមកហើយ ជាពិសេសយើងជាអ្នកលក់ត្រីស្រស់ៗនៅក្នុងក្រុង ។ បន្ថែមពីលើលក់ត្រីស្រស់ យើងមានលក់បន្លែសម្រាប់ម្ហូបអាស៊ី ។

**យើងទទួលយក :** American Express -លុយសុទ្ធ -Debit card -Master Card -Visa

**បើកទ្វារ :** ថ្ងៃច័ន្ទ ម៉ោង ៩:៣០ព្រឹក ដល់៧ល្ងាច/ ថ្ងៃអង្គារ៍ ដល់ថ្ងៃសៅរ៍ ៩:៣០ដល់៨ល្ងាច/ ថ្ងៃអាទិត្យ ៩:៣០-៧:០០




**ទីផ្សារចតរថយន្តឥតគិតថ្លៃ**



## តមកពីទំព័រទី ១ ខ្មែរនៅ Danbury មានជីវភាព...

ចុះប្រជាពលរដ្ឋខ្មែរឯទៀតៗមានជីវភាពរបៀបណា?

លោក តុង អឿង អាយុ៦០ឆ្នាំ មកដល់ "ដាន់ប៊ូរី"២៩ឆ្នាំហើយ ។

លោកនៅចាំថា នៅពេលមកដល់នាឆ្នាំ ១៩៨៣-៨៤ នោះ នៅដាន់ប៊ូរី នេះមានខ្មែរ ច្រើនដូចនៅឡូវែលអ៊ីចឹង តែដោយសារតែការងារតិចនៅពេលនោះ? មនុស្សជាច្រើនបានចាកចេញជាបន្តបន្ទាប់ ឥឡូវ នៅសល់ប្រមាណ៣000នាក់ប៉ុណ្ណោះ ។

លោកបន្តថា អ្នករស់នៅទីនេះ មានជីវភាពប្រសើរជាងតំបន់ឯទៀត ដោយសារឥឡូវសម្បូរ


លោក តុង អឿង

រោងចក្របានផ្ដល់ការងារច្រើនឱ្យពលរដ្ឋធ្វើគ្រប់ៗគ្នា ចំណែករូបលោកមានហាងបោកគក់ខោអាវស្ងួត មានចុះចំនួនភ្ញៀវច្រើនដែរ តែមិនយ៉ាប់ពេកទេ ដោយសារតែវិបត្តិសេដ្ឋកិច្ចអាមេរិកាំងនោះ ។ លោកបន្តថា ដោយសារភាពធូរធានៃគ្រួសារនីមួយៗគ្មានក្រុមក្មេងខិលខូច កូនរៀនសូត្របាន


លោក ត្រា យៀង

ល្អ មានចរិកចេះគោរពចាស់ទុំ ឪពុកម្ដាយក៏បានសុខសប្បាយ ។ វត្តខ្មែរឥឡូវមានពីដោយវត្តចាស់នៅ "ហាស់ហ្វីត" ត្រូវប្ដូរទៅបង្កើតថ្មីនៅ "ញូថោន" វត្តនោះមានព្រះសង្ឃ៥អង្គគង់នៅ ។

លោក ត្រា យៀង អាយុ៤៦ឆ្នាំមានកូន២នាក់មកដល់ដាន់ប៊ូរី ឆ្នាំ១៩៩៨ គឺបាន១៤ឆ្នាំហើយ ។ ខ្មែរនៅដាន់ប៊ូរី នេះ ចេះជួយយកអាសារសាមគ្គីគ្នាណាស់ គេជួបជុំគ្នានៅផ្ទះឬពេលធ្វើបុណ្យនៅវត្តគ្មានជម្លោះខ្វែងគំនិត ជាគណបក្សនោះទេ ។ ម្នាក់ៗប្រកបដោយរបររកស៊ីតាមជីវភាពផ្ទាល់ខ្លួនស្ងៀមស្ងាត់ ចិញ្ចឹមកូនឱ្យរៀនសូត្របានល្អ ឥតមានក្មេង ថ្វីត្បិតតែស្ថិតនៅចម្ងាយប្រមាណ១ម៉ោងឆាយណាថោននៃញូយ៉កក៏ដោយ ។ ខ្មែរនៅទីនេះឥតចូលចិត្តធ្វើនយោបាយធ្វើការងារស្រួលធ្វើនៅមិនឆ្ងាយពីផ្ទះដោយសាររោងចក្រច្រើនគ្មានធ្វើជប់លៀងរាំរែកនាពេលចូលឆ្នាំអីទេ ដោយសារគ្មានសមាគមតែក៏អាចប្រមូលផ្ដុំគ្នាកំសាន្តខារ៉ាអូខេតាមផ្ទះបានដែរ ។ ទីនេះមានហាងលក់ម្ហូបអាហារអាស៊ីប្រើសាច់


James chuong

ស្រស់ៗ ដូចជា Atlantic Market ឬក៏ខ្មែរលាវ TBS Asean ជាហាងធំៗ សម្រាប់លក់ឱ្យភ្ញៀវខ្មែរ យួន លាវ ស្បានីស ឬហ្វីលីពីន ។

យុវជន James chuong អាយុ១៨ឆ្នាំរៀននៅមហាវិទ្យាល័យផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ- James និយាយខ្មែរបានច្បាស់ ហើយថា ក៏ធ្លាប់មានយុវជនឯទៀតហុចបារីញៀនឱ្យខ្លួនតែមិនទទួលសុខចិត្តយកពេលទំនេរទៅទាត់បាល់ ឬលេងបាល់ឱបជាដើម ។ ឪពុកម្ដាយខ្ញុំជាអ្នកជួយជ្រោមជ្រែងខ្ញុំបានល្អណាស់ ខ្ញុំគ្មានខ្វះខាតអ្វីទេ សម្រាប់ការសិក្សាខ្ញុំនៅ Naugatuk Valley Community College" ។

នៅ Danbury បងប្អូនខ្មែរមានការងារធ្វើគ្រប់គ្នាគ្មានការងារ "លុយសុទ្ធ" ទេ គ្មានសមាគមខ្មែរទេ តែគឺជាសហគមន៍រីករាយមានសុភមង្គលនឹងអនាគតល្អ ៕


**Accepting New Clients**

សូមស្វាគមន៍ដល់ភ្ញៀវគ្រប់ប្រភេទ

Immigration • Divore • Auto Crash

អន្តោប្រវេសន៍ គ្រោះថ្នាក់រថយន្ត លែងលះប្ដីប្រពន្ធ

**Law Office of Thomas Stylianos Jr. • 287 Appleton St. Lowell MA 01852**

ការិយាល័យ មេធាវី ថូម៉ាស ស្ដាលីយ៉ាណូស

Call: Sophea or Thomas សូមទូរស័ព្ទមក: សោភា, ឬថំ

**978-459-5000 or 800-308-3766**

Only Licensed in Massachusets

**ANGKOR AUTO SERVICE, INC.**

ហាងជួសជុលរថយន្ត "អង្គរ"

Free Estimate

**Auto Body and Maintenance**

BODY WORKS

Auto glass and windshields

Auto Frame Straightening and Painting



មានបទពិសោធន៍២០ឆ្នាំ ជាជាងរថយន្តមានសញ្ញាប័ត្រវាយតម្លៃការងារដោយឥតយកថ្លៃ ហើយយើងជួយសន្សំប្រាក់តម្លៃបន្ថយរបស់អិនស្វ៊ូរិនបានផង យើងផ្ដល់សេវាគ្រប់យ៉ាង :

ENGINE AND TRANSIMISSION SERVICES

State Inspection
Check Engine Light Diagnostic
Timing Belt Services
Complete Tune Up:
-Brake -Muffler -Struts
-Water Pump -A/C
-Bearing Services

From the moment you get into car accident, we will take care of you from towing to calling your insurance, and to get a rental car for you. With Angkor Auto, you can be worried free.



4835 N. 16th Street. Philadelphia, PA 19141

Tel : (215) 455-7810 / Ricky : (215) 485-1425



ហាងខ្មែរជួសជុលរថយន្ត

បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ

**Rathe's Auto Service**

State and Emission Inspaction General Repairs and Maintenance

MON-SAT, 8:30AM-5:30PM
SUN. EMERGENCY ONLY




- ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
- មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
- មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ
- មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : - ដូរប្រេងក៏រិត ៥ ក្វាត $22
- INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់ -មានជូនប័ណ្ណពិសេសសំរាប់ដូរប្រេងចុះថ្លៃពាក់កណ្ដាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
- តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត ។
- ប្ដេជាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ។ ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬ ធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL : (215) 329-2418
Fax : (215) 329-2419. Rath CELL : (215) 431-6376

## តមកទំព័រទី ៦ លោក អូបាម៉ា ជំរុញឱ្យលោក ហ៊ុន សែន ...

គេថានោះទេ បើធៀបនឹងសិទ្ធិមនុស្ស និងសិទ្ធិនយោបាយនៅក្នុងប្រទេសជិតខាង"។

លោក សុខុន បានបន្តថា "ក្នុងប្រទេសរបស់យើងនយោបាយគឺបើកចំហសម្រាប់គ្រប់គណបក្សនយោបាយទាំងអស់ ហើយគណបក្សប្រឆាំងមានសិទ្ធិធ្វើអ្វីមួយដោយស្របតាមច្បាប់"។

នៅមុនពេលបំពេញដំណើរទស្សនកិច្ចរបស់លោក អូបាម៉ា ត្រូវបានជំរុញឱ្យដាក់សម្ពាធទៅលើលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ឱ្យលើកលែងទោសលោក សម រង្ស៊ី មេដឹកនាំគណបក្សប្រឆាំងដែលបច្ចុប្បន្នកំពុងតែរស់នៅដោយនិរទេសខ្លួនឯង ដើម្បីគេចចេញពីការផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេល១១ឆ្នាំ តាមការចោទប្រកាន់ជាច្រើនករណី ហើយគេជឿថា ការផ្តន្ទាទោសនេះ គឺជារឿងនយោបាយ។

លោក សុខុន មានប្រសាសន៍ថា ឈ្មោះ មេដឹកនាំគណបក្សប្រឆាំងរូបនេះ មិនត្រូវបានបង្ហាញទេ ក៏ប៉ុន្តែនេះជាការលើកឡើងចំពោះរឿងក្តីរបស់ សម រង្ស៊ី ។ លោកមានប្រសាសន៍ថា "សម្តេចបានបញ្ជាក់យ៉ាងច្បាស់ថា នៅក្នុងប្រទេសកម្ពុជា មិនមានអ្នកទោសនយោបាយទេ ពីព្រោះពីព្រោះបុគ្គលនោះ បានប្រព្រឹត្តខុស ដូច្នេះបុគ្គលនោះត្រូវតែប្រឈមមុខនិងច្បាប់"។

លោក ហ៊ុន សែន ក៏បានថ្លែងប្រាប់លោកប្រធានាធិបតីសហរដ្ឋអាមេរិក បារ៉ាក់ អូបាម៉ា ផងដែរថា សេចក្តីរាយការណ៍អំពីការបណ្តេញប្រជាពលរដ្ឋចេញក្នុងទ្រង់ទ្រាយធំនោះ គឺជារឿងបំផ្លើស។

លោកបានថ្លែងបន្តថា "ចំពោះបញ្ហាដីធ្លី និងការបណ្តេញចេញដោយបង្ខំ សម្តេចបានទទួលស្គាល់ថា មានបញ្ហាបែបនេះខ្លះៗបានកើតមានឡើងមែនដោយសារមានប្រជាពលរដ្ឋមួយចំនួនបានទៅរស់នៅលើដីដោយខុសច្បាប់ ដូច្នេះ(រដ្ឋាភិបាល)ត្រូវតែបង្ខំចិត្តអនុវត្តន៍តាមច្បាប់បណ្តេញពួកគេចេញ"។

សម្តេចបានព្យាយាមអះអាងចំពោះលោក អូបាម៉ា ថា ករណីទាំងនោះកម្រនឹងកើតឡើងណាស់។

ក្រុមអង្គការសិទ្ធិមនុស្សលើកឡើងថា ការផ្តល់ដីសម្បទានសេដ្ឋកិច្ចរបស់រដ្ឋាភិបាលឱ្យទៅក្រុមហ៊ុនឧស្សាហកម្ម និងក្រុមហ៊ុនជីករ៉ែបង្កឱ្យមានបញ្ហាសិទ្ធិមនុស្សយ៉ាងធ្ងន់នៅទូទាំងប្រទេស



ជំទាវ ប៊ុន រ៉ានី គួរសមជាមួយ អូបាម៉ា ក្រោមក្រសែភ្នែក ហ៊ុន សែន

មានសេចក្តីរាយការណ៍និងហេតុការតវ៉ាដែលទាមទារឱ្យមានការដោះអ្នក ទោសនយោបាយទាំងអស់ ។សម្តេចបានមានប្រសាសន៍ថា មិនមានអ្នកទោសនយោបាយនៅក្នុងប្រទេសកម្ពុជាទេ ក៏ប៉ុន្តែសម្តេចមានប្រសាសន៍ ថា អ្នកទោសនយោបាយខ្លះគឺជាជនល្មើស គឺជាអ្នកនយោបាយដែលល្មើសច្បាប់ ។ ដូច្នេះអ្នកនយោបាយត្រូវតែបានកាត់ទោសតាមច្បាប់"។

លោកបានមានប្រសាសន៍បន្ថែមថា លោក អូបាម៉ា ពិតជាបានលើកករណីលោក ម៉មសូណង់ដូរ ម្ចាស់ស្ថានីយ៍វិទ្យុដ៏ប្រជាប្រិយ៍ភាពមួយរូបនិងជាអ្នករិះគន់រដ្ឋាភិបាល ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល២០ឆ្នាំ ពីបទចោទប្រកាន់ថា បានដឹកនាំចលនាអបគមន៍នោះ ក៏ត្រូវបានថ្កោលទោសជាទូទៅថា ជារឿងនយោបាយដែរ។

លោក សុខុន មានប្រសាសន៍បន្តទៀតថា "សម្តេចបានពន្យល់ថា មានការយល់ច្រឡំថា មានការប៉ុនប៉ងបិទស្ថានីយវិទ្យុនោះ ។ តាមការពិតស្ថានីយវិទ្យុនោះកំពុងតែដំណើរ ហើយនៅតែពេញនិយមសម្រាប់អ្នកស្តាប់ ។ ស្របពេលជាមួយគ្នានេះដែរ សម្តេចក៏បានសង្កត់ធ្ងន់ថា វាគឺជារឿងបុគ្គលដែលត្រូវប្រឈមមុខ នឹងច្បាប់និងធ្វើឱ្យប៉ះពាល់ដល់ប្រជាពលរដ្ឋជាង៤០០.០០០នាក់ក្នុងរយៈពេលមួយទសវត្សរ៍មកនេះ។

លោកសុខុន បានមានប្រសាសន៍បន្តថា លោកនាយករដ្ឋមន្ត្រីពិតជាបានលើកឡើងយ៉ាងហោចណាស់ពីបញ្ហាមួយរបស់លោកផ្ទាល់ គឺបញ្ហាបំណុលដែលមានការប្រាក់ជាង៤០០លានដុល្លារ ដែលប្រទេសកម្ពុជា នៅជំពាក់អាមេរិក ក្នុងរដ្ឋាភិបាល លន់ នល់ កាលពីទសវត្សរ៍ឆ្នាំ១៩៧០។

លោកបានមានប្រសាសន៍បន្តទៀតថា លោក ហ៊ុន សែន បានលើកឡើងជាថ្មីម្តងទៀតថា កម្ពុជាសូមសងតែ៣០ភាគនៃបំណុលនេះ ដែលមានការប្រាក់មួយភាគរយប៉ុណ្ណោះ ហើយបានយល់ព្រមចំពោះការប្រាក់ដែលត្រូវសងចំពោះសហរដ្ឋអាមេរិកនោះ លើផ្នែកអប់រំការបោសសម្អាតគ្រាប់មីន និងគម្រោងវប្បធម៌។

ស្ថានទូតសហរដ្ឋអាមេរិក មិនបានឆ្លើយតបភ្លាមៗចំពោះសំណើរសុំសេចក្តីអត្ថាធិប្បាយពីករណីនេះទេ។

លោក បារ៉ាក់ អូបាម៉ា ធ្វើដំណើរមកកាន់ប្រទេសកម្ពុជា ដើម្បីចូលរួមក្នុងកិច្ចប្រជុំកំពូលអាស៊ាន និងអាស៊ីបូព៌ា ហើយមានគម្រោងចេញដំណើរពីកម្ពុជានៅថ្ងៃទី២០ទៅកាន់ប្រទេសជប៉ុន៕

## តមកទំព័រទី ១ ឡូវែល : សហគមន៍ខ្មែរ...

លោក ខេវិន ខហ្វលីន Kevin Coughlin ជាប្រធានគណកម្មាធិការនាយក និងលោក រ៉ាស៊ី អាន Racy An ជានាយកប្រតិបត្តិនៃសមាគមខ្មែរ ជាតារាឯកនៃរាត្រីសមោសសមាគមដែលបានដឹកនាំកម្មវិធីបង្ហាញស្នាដៃបានបំពេញពីអតីតកាលបច្ចុប្បន្នកាល នឹងគោលបំណងទៅអនាគតជូនដល់ភ្ញៀវនឹងកំដរដោយក្រុមតន្ត្រីខ្មែរ ទាំងជំនាញពេញមួយរាត្រីផង។

លោក ខេវិន ខហ្វលីន បានបង្ហាញជាពិសេសនៃភោជនីយដ្ឋានប៉ៃលិន មានការបង្ហាញខ្លួនបុគ្គលិក និងសកម្មភាពវប្បធម៌ខ្មែរ ហើយភ្ញៀវពិសេសពីររូបបានទទួលរង្វាន់កោតសរសើរពីសមាគមខ្មែរ ដោយសារបានបំពេញតួនាទីជាអ្នកបំរើសហគមន៍ខ្មែរបានប្រសើរ គឺលោកវ៉ាស្នា នួន នឹងអ្នកស្រី សូភី ធីម។ លោក វ៉ាស្នា នួន ជាគណក្រុមប្រឹក្សាឡូវែល បានសំដែងការអរគុណ និងកោតសរសើរដល់សមាគម ហើយក៏កោតសរសើរដល់ពលរដ្ឋខ្មែរនៅឡូវែល ដែលបានចេញ



នាង សូភី ធីម ទទួលរង្វាន់ពីសមាគមខ្មែរ



លោក វ៉ាស្នា នួន ក៏ទទួលរង្វាន់ដូចគ្នាដែរ

ក្នុងនាមនៃគណកម្មាធិការនាយក នូវបំណងចំបងមួយ ប្រមូលសហគមន៍ខ្មែរឱ្យនិយាយភាសាតែមួយ ក្នុងរូបភាពរួបរួមសាមគ្គីអភិវឌ្ឍន៍គ្រួសារខ្មែរនៅឡូវែលឱ្យរឹតតែប្រសើរឡើង នាពេលឆាប់ៗខាងមុខ ។ នៅក្នុងសកម្មភាពដ៏លំបាកមួយទៀត លោក រ៉ាស៊ី អាន បានបង្ហាញពីការបន្ថយចំនួនបុគ្គលិកបំរើការងារសមាគម ដោយយោងទៅតាមធនធានដែលត្រូវបានកាត់បន្ថយនៃអ្នកផ្តល់ជំនួយ ក៏ប៉ុន្តែសមាគមមានដំណើរការដូចពីមុនមកដដែល ។ ទោះជាអម្រែកកាន់តែធ្ងន់ចំពោះបុគ្គលិកដែលនៅសល់ សមាគមនៅតែបន្តសកម្មភាពបង្ហាត់បង្រៀនអក្សរ សកម្មភាព ដើម្បីសុខភាពពលរដ្ឋ សកម្មភាពសិក្ខាសាលា ឬក៏សកម្មភាពបន្តស្វែងរកការទិញអគារថ្មីសំរាប់សមាគមជាដើម ។ល។

ក្នុងពេលភ្ញៀវពិសារភោជនាហារយ៉ាងឆ្ងាញ់រៀបចំយ៉ាងសមរម្យ ជាពិធីទទួលភ្ញៀវដ៏សំខាន់ទៅបោះឆ្នោត បំពេញភារកិច្ចចំបងជាពលរដ្ឋទទួលខុសត្រូវ ហើយចុងក្រោយនេះបានធ្វើឱ្យប្រធានាធិបតីប្រជាធិបតេយ្យម្នាក់ជាប់ឆ្នោតសារជាថ្មី ហើយជាពិសេសធ្វើឱ្យតំណាងរាស្ត្រ និងមន្ត្រីគណបក្សប្រជាធិបតេយ្យនៅឡូវែលបានជាប់ឆ្នោតទាំងអស់គ្នាទៀតផង មានទាំងបញ្ជូនតំណាងស្ត្រីនៅឡូវែលម្នាក់ទៅធ្វើការនៅសភាជាតិ នារដ្ឋធានីវ៉ាស៊ិនតោនថែមទៀត គឺលោកសង្ឃឹមថា "តទៅមុខ ពលរដ្ឋខ្មែរយើងមានកម្លាំងគ្រប់គ្រាន់ ដើម្បីជ្រើសរើសតាំងនរណាក៏បានឱ្យធ្វើជាមន្ត្រីនៅឡូវែលយើងនេះ" ។

រាត្រីសមាគមខ្មែរ បានបញ្ចប់យ៉ាងរីករាយដោយគេមិនភ្លេចនូវភ្លេងពីរោះស្តាប់ នឹងចំរៀងស្នេហាជាតិ ឬមនោសញ្ចេតនារបស់លោក រ៉ាឌី ម៉ម នឹងអតីតគណក្រុមប្រឹក្សាក្រុងឡូវែល អ៊ុង រិទ្ធី ដែលច្រៀងរឹតតែពិរោះជាងពេលមុនៗ ធ្វើឱ្យបរិយាកាសរឹតតែមានមិត្តភាពបរិបូរណ៍៕

## Sea...

**Continue From page 19**

a mutually reinforching objective of Asean unity and addressing this issue in a matther they see fit," Mr.Natalegawa said in an interview on the sidelines to yesterday´s meeting.

"I don´t think we should be too preoccupied with the labels it´s internationalized´ or not," he added.

"From the very beginning, this issue is one that is receiving attention both at the bilateral level between the afftected countries and at the same time, at the regional context,"

Since Cambodia assumed the chairmanship of Asean, there has been a distinct bloc over how to handle the issue of the South China Sea.

During the Asean Summit in April, Cambodia pushed for China´s involvement in Asean discusions on major piont i n the drafting of a legally binding Code of Conduct (COC) in the sea. How ever, the Philippine disagreed with China´s inclusion, stating that key clements in the COC should be decided within Asean before including China.

Analyst said this week´s Asean Summit is merely a repeat of the traditional allegiances that have come to light throughout the year.

On Sunday, Chinese.Premire Wen Jiabao pledged more than $50 milion in aid to cambodia during a meeting with Prime Minister Hun Sen.

"This does appear to be another example of Cambodia trying to purue its single-minded policy of not giving any offense to China," said Carlyle Thayer, a profecssor at the University of New South Wales at the Australian Defense Force Academy who is an expert on the regon.

"Cambodia´s actions only serve to undermine the Asean Chair as an office," he added.

*(Additional reporting by Colin Meyn)*

# ប្រាសាទភ្នំដា តំបន់អតីត: រាជធានីដំបូងរបស់ខ្មែរ





នារដូវវស្សានេះប្រាសាទភ្នំដាព័ទ្ធជុំវិញទៅដោយផ្ទៃទឹកល្ហាចល្ហឹមបង្កើតជាសោភណភាពស្រស់ត្រកាល គួរឱ្យចង់គយគន់ក្រៃលែង។ បើលោកអ្នកបានទៅដល់ទីនោះដូចជាស្ថិតនៅលើកូនកោះដែលមានប្រាសាទបុរាណដ៏ចំណាស់នៅកណ្ដាលផ្ទៃជលសា គួរជាទីរីករាយក្នុងចិត្ត និងស្ថិតនៅតំបន់អតីតរាជធានីដំបូងបង្អស់របស់ខ្មែរនៃនគរភ្នំ និងជាកន្លែងចាប់កំណើតអារ្យធម៌ខ្មែរ ។

○○○រមណីយដ្ឋានវប្បធម៌-ប្រវត្តិសាស្ត្រភ្នំដា បើលោកអ្នកចង់ទៅកម្សាន្តត្រូវធ្វើដំណើរចេញពីភ្នំពេញឆ្ពោះទៅទិសខាងត្បូងតាមបណ្ដោយផ្លូវជាតិលេខ២ប្រមាណ៧៧គីឡូម៉ែត្រ ដល់ទីរួមខេត្តតាកែវ រួចបន្តដំណើរតាមអូប័រប្រហែល ៤០នាទីតាមបណ្ដោយព្រែកជីកលេខ១៥នឹងទៅដល់ហើយ ។ ម្យ៉ាងវិញទៀតបើលោកអ្នកធ្វើដំណើរតាមរថយន្ត ឬម៉ូតូចេញពីភ្នំពេញឆ្ពោះទៅទិសខាងត្បូងតាមបណ្ដោយផ្លូវជាតិលេខ២ដដែលដល់ប្រាសាទនាងខ្មៅ ឬដល់ផ្លូវចូលប្រាសាទភ្នំជីសូរបន្តដំណើរឆ្ពោះទៅទិសខាងកើត លុះដល់ផ្សារព្រៃល្វាបត់ស្ដាំឆ្ពោះទៅទិសខាងត្បូងត្រង់ប្រមាណ២៤គីឡូម៉ែត្រ នោះលោកអ្នកនឹងទៅដល់ប្រាសាទភ្នំដា ។

បើយោងតាមប្រសាសន៍របស់មន្ត្រីទេសចរណ៍ប្រចាំការនៅរមណីយដ្ឋានភ្នំដាបានឱ្យដឹងថា រមណីយដ្ឋាននេះស្ថិតនៅក្នុងភូមិព្រែកតាផ ឃុំគោកធ្លក ស្រុកអង្គរបុរី ។ ប្រាសាទភ្នំដាកសាងឡើងនៅសតវត្សទី៦ក្នុងរាជ្យព្រះបាទរុទ្រវរ្ម័នក្នុងសម័យកាលហ្វូណនធ្វើអំពីថ្មបាយក្រៀមថ្មភក់ និងឥដ្ឋ ។

ប្រាសាទនេះមានកម្ពស់១៨ម៉ែត្រ និងមានទំហំ១២ម៉ែត្រការ៉េ ស្ថិតនៅលើកំពូលភ្នំកម្ពស់ប្រហែល ៥០ម៉ែត្រ ។ ប្រាសាទបុរាណភ្នំដាមានទ្វារចំនួន៤ តែមានតែទ្វារមួយគត់ដែលអាចចេញចូលបានគឺទ្វារស្ថិតនៅទិសខាងជើង ។ ភ្ញៀវទេសចរអាចឡើងទៅទស្សនាប្រាសាទនេះបានតាមរយៈជណ្ដើរទិសខាងជើង និងជណ្ដើរទិសខាងលិចដែលបានកសាងឡើងកាលពីប៉ុន្មានឆ្នាំកន្លងមកថ្មីៗនេះ ។ តាមជណ្ដើរឡើងទៅលើកំពូលភ្នំមានដើមឈើធំៗបង្កឱ្យមានម្លប់ត្រជាក់ដល់ភ្ញៀវទេសចរ ។

ចំពោះការអភិវឌ្ឍន៍ផ្សេងៗនៅរមណីយដ្ឋានភ្នំដានោះ កាលពីប៉ុន្មានឆ្នាំមុនមិនមានផ្លូវសម្រាប់បង្កភាពងាយស្រួលដល់ភ្ញៀវទេសចរទៅកម្សាន្តទេ ដោយសារតែតំបន់ភ្នំដាស្ថិតនៅវាលទំនាបបឹង ដូច្នេះក្នុងរដូវវស្សាមានភក់ស្អិត ។ កត្តានេះហើយ ទើបមិនសូវមានភ្ញៀវទៅទស្សនាកម្សាន្ត ។ ក្នុងពេលថ្មីៗនេះ ដោយសារមានការយកចិត្តទុកដាក់ពីមន្ទីរទេសចរណ៍ខេត្តតាកែវ ក៏បានអភិវឌ្ឍន៍រមណីយដ្ឋានភ្នំដាឱ្យមានភាពប្រសើរជាងពេលមុនច្រើន ជាពិសេសនោះកសាងផ្លូវគ្មានភក់ជ្រាំស្អិតដូចកាលពីមុនទៀតទេ ហេតុដូចនេះហើយ ទើបមានការកើនឡើងទាំងភ្ញៀវជាតិ និងអន្តរជាតិបាននាំគ្នាមកទស្សនាច្រើននារដូវភ្ជុំបិណ្ឌក៏ ដូចជាថ្ងៃបុណ្យផ្សេងៗ និងថ្ងៃឈប់សម្រាកផងដែរ ។











មន្ត្រីទេសចរណ៍ប្រចាំការនៅភ្នំដាបានបញ្ជាក់ឱ្យដឹងទៀតថា នៅចង្កេះភ្នំដាមានរូងប្រាំដែលកសាងឡើងតាំងពីប៉ុន្មានឆ្នាំមុនគ្រិស្តសករាជសម្រាប់ជាទីកន្លែងគោរពបូជា ។ ចំណែកនៅភាគខាងលិចប្រមាណពី៣០ទៅ៤០ម៉ែត្រពីប្រាសាទភ្នំដាមានប្រាសាទមួយទៀតឈ្មោះអាស្រមមហាឥសី កសាងឡើងនៅចុងសតវត្សទី៦នាសម័យកាលចេនឡាដោយស្ដេចភវវរ្ម័នទី១ ។ រមណីយដ្ឋានភ្នំដានារដូវវស្សា ប្រៀបបីដូចជាកូនកោះតូច មួយដែលហ៊ុមព័ទ្ធទៅដោយទឹកល្ហាចល្ហឹមធ្វើឱ្យ ទេសភាពកាន់តែស្រស់ស្អាតទ្វេដងថែមទៀត ។

នៅពេលភ្ញៀវទេសចរបានទៅកម្សាន្តនៅ រមណីយដ្ឋានវប្បធម៌-ប្រវត្តិសាស្ត្រភ្នំដាមិនត្រឹម តែបានឃើញប្រាសាទបុរាណដ៏មានវ័យចំណាស់ ប៉ុណ្ណោះទេ ប៉ុន្តែបានឃើញតំបន់ដែលជាអតីត រាជធានីដំបូងរបស់ខ្មែរនៃនគរភ្នំ និងជាកន្លែងចាប់ កំណើតអារ្យធម៌ខ្មែរទៀតផង ៕